# ព្រឹទ្ធសភា

# *SENATE MAGAZINE*

ទស្សនាវដ្ដីប្រចាំខែមេសា



លេខ ២៥៨ ឆ្នាំទី២២

ពុទ្ធសករាជ ២៥៦៥ គ្រិស្តសករាជ ២០២២

Issue 258 Volume 22

Before Christ 2565 Common Era 2022

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សារជូនពររបស់សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦........១
- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពិនិត្យសម្រេចលើរបៀបវារៈចំនួន២........................៣
- ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី៨ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ ..........................................................................................៤
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបប្រធានរដ្ឋសភាឥណ្ឌា....................................................៦
- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំគណៈប្រតិភូសភាកម្ពុជាបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ.......................៨
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ..........................................................................១២


## សកម្មភាពគណៈកម្មការ




- គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥សំណេះសំណាលថ្នាក់ដឹកនាំស្រុក និងក្រុមប្រឹក្សាឃុំក្នុងស្រុកត្រាំកក់...................................................... ១៥
- គណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាលក្រុមប្រឹក្សាឃុំទាំង៥ នៃស្រុករតនមណ្ឌល ខេត្តបាត់ដំបង.......................................................................................................១៦
- គណៈកម្មការទី២ព្រឹទ្ធសភាសំណេះសំណាលក្រុមប្រឹក្សាឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ............................................................................................................................១៧
- គណៈកម្មការទី៣ព្រឹទ្ធសភាឈ្វេងយល់អំពីការអនុវត្តច្បាប់ និងសម្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួននៅខេត្តកំពង់ស្ពឺ ..................................................................................................១៨
- គណៈកម្មការទី៥ព្រឹទ្ធសភាអញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុនសែន ខេត្តពោធិ៍សាត់ សហគមន៍តម្បាញ មជ្ឈមណ្ឌលបកគ្រាប់ស្វាយចន្ទី និងសហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ ........................ ១៩
- គណៈកម្មការទី៥ព្រឹទ្ធសភាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន នៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត..........................................................................................២០
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២សំណេះសំណាលអាជ្ញាធរក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តកំពង់ចាម ..........២១
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥សំណេះសំណាលថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងខេត្តតាកែវ....... ២២
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦សំណេះសំណាលក្រុមប្រឹក្សាឃុំក្នុងស្រុកស៊ីធរកណ្តាល ស្រុកកំចាយមារ ស្រុកកញ្ជ្រៀច និងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង.................................................................... ២៣
- ឯកឧត្តម សុខ ឥសាន់ សំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ក្នុងស្រុកកំពង់ត្របែក ស្រុកព្រះស្តេច និងស្រុកពាមរក៍ ខេត្តព្រៃវែង...............................................................................................២៤
- ក្រុមសមាជិកាព្រឹទ្ធសភាសំណេះសំណាលសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់មកពីខេត្តកំពត និងខេត្តកែប...........................២៥
- ឯកឧត្តម សុខ ឥសាន ផ្តល់អនុសាសន៍ចំនួន២ចំណុច ដើម្បីប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងសេរីភាពសារព័ត៌មាន ........ ២៧
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា............................................................២៨
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨...........................................៣១
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ..........................................................................៤២
- ការងារទទួលពាក្យបណ្តឹង.......................................................................................................៤៤


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងកំណត់ទិសដៅការងារខែមេសា ឆ្នាំ២០២២..................................................................................៤៥
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ និងលើកទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២២ ................................................................................ ៤៦
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ...............................៤៧



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខធី

លោក ទេព មករា

លោក កុក រ៉េ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

កញ្ញា សុខ សុជាតា


ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយជាមួយនឹងឯកឧត្តម Park Byeong-seug ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ។

ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយជាមួយនឹងគណៈប្រតិភូសភា នៃសាធារណរដ្ឋឥណ្ឌា។


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរសព្ទ: (855 23)211441, 211442, 211443,ទូរសារ: (855 23)211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា



# សារជូនពរ

## របស់សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះរាជាគណៈ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- សូមក្រាបបង្គំទូលថ្វាយសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ
- សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី ជាទីគោរពស្នេហា
- បងប្អូនជនរួមជាតិ ជាទីគោរពរាប់អាន

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ដែលប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ទី១៤ ថ្ងៃសុក្រ ទី១៥ និងថ្ងៃសៅរ៍ ទី១៦ ខែមេសា ឆ្នាំ២០២២ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំសូមចូលរួមអបអរសាទរជាមួយនឹងជនរួមជាតិទាំងអស់ សូមទទួលបានពរជ័យ សិរីសួស្តី បវរមហាប្រសើរ វិបុលសុខគ្រប់ប្រការ និងទទួលបានជោគជ័យថ្មីៗបន្ថែមទៀត។

មហាសង្ក្រាន្តបីថ្ងៃនេះ ជាឱកាសឱ្យប្រជាពលរដ្ឋយើងរួមគ្នាជម្រះចោលឱ្យជ្រះស្រឡះនូវភាពអពមង្គល ឧបទ្រពចង្រៃ និងមន្ទិលហ្មងសៅទាំងពួងក្នុងឆ្នាំចាស់ ហើយតាំងចិត្តថ្មីប្រព្រឹត្តអំពើល្អ ប្រកបដោយ មេត្តា ករុណា មុទិតា ឧបេក្ខា និងបញ្ញានៅក្នុងឆ្នាំថ្មី។

ក្រោមម្លប់ដ៏ត្រជាក់ត្រជុំ នៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្រោមដំបូលនៃរដ្ឋធម្មនុញ្ញ និងលើមូលដ្ឋាននៃមហាសាមគ្គី ឯកភាពជាតិរឹងមាំ ដំណើរទៅមុខរបស់ជាតិយើងប្រព្រឹត្តទៅដោយរលូន និងមានជោគជ័យជាបន្តបន្ទាប់។

ឆ្នាំ២០២០ និងឆ្នាំ២០២១ កន្លងទៅនេះ វិបត្តិជាសកលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើជីវភាពសង្គមជាតិយើង។ ប្រឈមនឹងស្ថានការណ៍នេះ រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខដ៏ឆ្នើម បានដាក់ចេញផែនការយុទ្ធសាស្ត្រ និងវិធានការជាច្រើនប្រកបដោយភាពជាក់ស្តែងក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺដ៏កាចសាហាវនេះ ទាំងខាងរដ្ឋបាល សុខាភិបាល សន្តិសុខ សេដ្ឋកិច្ច និងសង្គមកិច្ច ជាពិសេសយុទ្ធនាការជាតិចាក់វ៉ាក់សាំង ដើម្បីការពារអាយុជីវិតប្រជាជន រក្សាស្ថិរភាពសង្គម រក្សាលំនឹងសេដ្ឋកិច្ច និងលំនឹងនៃជីវភាពរស់នៅដោយមានការចូលរួមយ៉ាងផុលផុសពីសំណាក់ប្រជាពលរដ្ឋ។ មកដល់ពេលនេះ ស្ថានភាពទូទៅកាន់តែបានល្អប្រសើរឡើងដែលឆ្លុះបញ្ចាំងអំពីជោគជ័យរបស់យើងក្នុងការទប់ស្កាត់មិនឱ្យប្រជាជនធ្លាក់ក្នុងគ្រោះមរណៈនៃជំងឺកូវីដ-១៩ និងបានផ្តល់ការរំពឹងទុកប្រកបដោយភាពវិជ្ជមានចំពោះការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញក្នុងឆ្នាំ២០២២នេះ។ ទោះបីជាដូច្នេះក្តី ក៏ជំងឺកូវីដ-១៩ នៅតែជាការគំរាមកំហែងយ៉ាងធំនៅឡើយដល់ការរស់នៅរបស់ប្រជាជនយើងដែលទាមទារឱ្យម្នាក់ៗត្រូវរៀនរស់ជាមួយកូវីដតាមគន្លងប្រក្រតីភាពថ្មី បន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានសុវត្ថិភាពនានា ជាពិសេសការចាក់វ៉ាក់សាំងឱ្យបានពេញលេញ និងការអនុវត្តវិធានការ “៣ការពារ ៣កុំ”។

ក្នុងឱកាសដ៏មហោឡារិកនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនប្រទេសជាមិត្តភក្តិជិតឆ្ងាយ ស្ថាប័ន អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដែលបានលើកទឹកចិត្ត និងជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ និងប្រជាពលរដ្ឋកម្ពុជា។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ព្រះបារមីទេវតារក្សាព្រះមហាស្វេតច្ឆត្រវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី និងព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ សូមទ្រង់ព្រះមេត្តាជួយប្រោះព្រំ ប្រទានពរជ័យ ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈ សូមព្រះអង្គមានព្រះជន្មយឺនយូរ ព្រះសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ត្រជុំសុខដុមរមនាសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី ថ្វាយសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ថ្វាយ និងប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងសូមប្រសិទ្ធពរ បវរមហាប្រសើរ ថ្វាយសម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ជូនសម្តេច ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និយោជក និយោជិត កម្មករ កសិករ ពាណិជ្ជករ អាជីវករ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ជនរួមជាតិក្នុង និងក្រៅប្រទេស សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **កិរិណីទេវី** ជួយអភិបាលគ្រប់គ្រងថែរក្សា និងប្រសិទ្ធពរជ័យ សិរីសួស្តីដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ឱ្យមានសមានចិត្តជាកុសល យោគយល់គ្នា សន្តោសប្រណី សាមគ្គី រួមសុខរួមទុក្ខជាមហាគ្រួសារតែមួយនៅលើទឹកដីមាតុភូមិអង្គរជាទីស្នេហា ដោយក្តីសុខក្សេមក្សាន្ត កិត្តិយស និងសេចក្តីថ្លៃថ្នូរតរៀងទៅ៕

ឆ្នាំថ្មី ការខិតខំថ្មី ជោគជ័យថ្មី!

# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពិនិត្យសម្រេចលើរបៀបវារៈចំនួន២



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាថ្ងៃអង្គារ ទី១៩ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានរបៀបវារៈចំនួន២គឺ៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ ទៅក្នុងរបៀបវារៈ សម័យប្រជុំលើកទី៨ ព្រឹទ្ធសភា នីតិកាលទី៤។**

**២-កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៨ព្រឹទ្ធសភា នីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃពុធ ទី២០ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្តសម័យប្រជុំលើកទី៨ព្រឹទ្ធសភា នីតិកាលទី៤ ដោយមានរបៀបវារៈតែមួយគឺ៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

(អត្ថបទ៖ ទេព មករា រូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា លើកដៃអនុម័ត*

# ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី៨ ដើម្បីពិនិត្យ និងឱ្យយោបល់ លើសេចក្ដីព្រាងច្បាប់ស្ដីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំការបន្តសម័យប្រជុំលើកទី៨ព្រឹទ្ធសភា នីតិកាលទី៤*

នាព្រឹកថ្ងៃពុធ ទី២០ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៨ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៩រូប។



*ឯកឧត្ដមបណ្ឌិត ម៉ុង ឫទ្ធី ឡើងអានរបាយការណ៍*

សេចក្ដីព្រាងច្បាប់នេះ ត្រូវបានឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឡើងធ្វើសេចក្ដីរាយការណ៍ជូនអង្គប្រជុំបានជ្រាបអំពីការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ។ សេចក្ដីព្រាងច្បាប់នេះ តាក់តែងឡើងដើម្បីកំណត់អំពីការគ្រប់គ្រងសុខភាពរុក្ខជាតិ ការអនុវត្តវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ ការការពារធនធានរុក្ខជាតិគ្រប់ប្រភេទ ការទប់ស្កាត់ការបង្កការឆ្លងរាលដាល និងការរាតត្បាតពីសំណាក់សមាសភាពចង្រៃ ការលើកកម្ពស់ផលិតភាពកសិកម្ម សន្តិសុខស្បៀង អនាម័យ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ព្រមទាំងសន្តិសុខភូតគាមអនាម័យនៃរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ការសម្រួលការធ្វើពាណិជ្ជកម្ម ការនាំចេញ ការនាំចូល ការដឹកជញ្ជូនឆ្លងកាត់នូវផលិតផលដំណាំ រុក្ខជាតិ និងផលិតផលរុក្ខជាតិ ព្រមទាំងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ និងការលើកកម្ពស់សុខុមាលភាព និងសុខភាពសាធារណៈ



*ទិដ្ឋភាពរួមក្នុងការបន្តសម័យប្រជុំលើកទី៨ព្រឹទ្ធសភា នីតិកាលទី៤*

ប្រកបដោយនិរន្តរភាពធនធានធម្មជាតិ និងប្រព័ន្ធក្បេត្រ បរិស្ថាន ដើម្បីធានាការគ្រប់គ្រង ការពាររុក្ខជាតិ និងភូតគាម អនាម័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីសមាជិកព្រឹទ្ធសភាមួយចំនួន បានពិនិត្យ និងលើកជាសំណួរ ព្រមទាំងផ្តល់យោបល់ជូនតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចមក ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឡើងបកស្រាយបំភ្លឺយ៉ាងក្បោះក្បាយ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែ ចំនួន៥៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ ទេព មករា រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តម វេង សាខុន ឡើងការពារសេចក្តីព្រាងច្បាប់*





*សមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តច្បាប់*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបប្រធានរដ្ឋសភាឥណ្ឌា



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ និងឯកឧត្តម OM BIRLA*

នាព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង១០:៥៥ នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួប ឯកឧត្តម OM BIRLA ប្រធានរដ្ឋសភា នៃសាធារណរដ្ឋឥណ្ឌា និងគណៈប្រតិភូដែលបានមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា។

សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា បានសម្តែងនូវសេចក្តីរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម OM BIRLA ដែលបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ សម្តេចបានបញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាពេលនេះ បានឆ្លុះបញ្ចាំងពីទំនាក់ទំនងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រជាជន និងប្រទេសទាំងពីរដែលមានស្រាប់ និងបន្តពង្រឹងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងកម្ពុជា និងឥណ្ឌា និងរវាងសភានៃប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើងថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន នៃប្រទេសទាំងពីរ ទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងនាមគណៈប្រតិភូ ឯកឧត្តម OM BIRLA បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រធានព្រឹទ្ធសភាដែលបានទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅប្រកបដោយក្តីរីករាយយ៉ាងរាក់ទាក់បំផុតចំពោះគណៈប្រតិភូ។ ឯកឧត្តមបានបញ្ជាក់ថា ក្នុងរយៈពេល៧ទសវត្សរ៍កន្លងទៅ ប្រទេសឥណ្ឌាមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងប្រទេសកម្ពុជា ហើយប្រទេសឥណ្ឌាបានទទួលស្គាល់នូវឯករាជ្យភាពរបស់ប្រទេសកម្ពុជាក្នុងទសវត្សរ៍ទី៥០ និងជាប្រទេសដំបូងដែលទទួលស្គាល់សាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងទស្សវត្សរ៍ទី៨០ ក្រោយរបបប្រល័យពូជសាសន៍ **ប៉ុល ពត**។

ឯកឧត្តម OM BIRLA បានអបអរសាទរចំពោះការចុះអនុស្សរណៈយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឥណ្ឌា កាលពីឆ្នាំ២០១៦កន្លងទៅ ក្នុងនោះមានមន្ត្រីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា បានចូលរួមវគ្គបណ្តុះបណ្តាលទៅតាមជំនាញជាក់ស្តែងជាង ២០០នាក់ និងមន្ត្រីក្របខ័ណ្ឌរបស់រាជរដ្ឋាភិបាលជាង២ពាន់នាក់ ក៏បានចូលរួមវគ្គបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការបច្ចេកទេស APTECH ផងដែរ។

ឯកឧត្តម OM BIRLA បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាជ្រាបថា រដ្ឋសភាឥណ្ឌាមានវិទ្យាស្ថានស្រាវជ្រាវ និងការបណ្តុះបណ្តាលសម្រាប់ប្រជាធិបតេយ្យ។ វិទ្យាស្ថាននេះបានរៀបចំវគ្គបណ្តុះបណ្តាល និងវគ្គតម្រង់ទិសជាច្រើនជូនដល់សមាជិកសភា ក៏ដូចជាអ្នករៀបចំគោលនយោបាយមន្ត្រីរដ្ឋការស៊ីវិល និងមន្ត្រីសភា។ ឯកឧត្តមបានអញ្ជើញសមាជិកព្រឹទ្ធសភា និងមន្ត្រី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ចូលរួមវគ្គបណ្តុះបណ្តាល នៅវិទ្យាស្ថានស្រាវជ្រាវ និងការបណ្តុះបណ្តាលសម្រាប់ប្រជាធិបតេយ្យ នៃរដ្ឋសភាឥណ្ឌា។

ឯកឧត្តមបានស្នើឱ្យសភានៃប្រទេសទាំងពីរ បង្កើននូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អប្រសើរឡើងថែមទៀត តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចទៅវិញទៅមក ទាំងក្នុងកម្រិតខ្ពស់ និងកម្រិតបច្ចេកទេស ដើម្បីឈ្វេងយល់បទពិសោធន៍ការអភិវឌ្ឍឱ្យល្អប្រសើររវាងសភា នៃប្រទេសទាំងពីរ។

ឯកឧត្តម OM BIRLA បានជម្រាបសម្តចប្រធានព្រឹទ្ធសភាជ្រាបថា នៅឆ្នាំ២០២២ គឺជាឆ្នាំនៃការប្រារព្ធខួបលើកទី៣០ នៃទំនាក់ទំនងអាស៊ាន-ឥណ្ឌា។ ក្នុងឱកាសនោះ ឯកឧត្តមបានគោរពអញ្ជើញថ្នាក់ដឹកនាំសភារបស់អាស៊ានបំពេញទស្សនកិច្ចនៅប្រទេសឥណ្ឌា ក្នុងនោះឯកឧត្តមក៏បានអញ្ជើញសម្តេចប្រធានព្រឹទ្ធសភាផងដែរ។

ឯកឧត្តម OM BIRLA បានថ្លែងអំណរគុណចំពោះប្រទេសកម្ពុជាដែលបានគាំទ្របេក្ខភាពរបស់ប្រទេសឥណ្ឌា ក្នុងក្របខ័ណ្ឌសមាជិកអចិន្ត្រៃយ៍ និងមិនអចិន្ត្រៃយ៍ នៃអង្គការសហប្រជាជាតិ ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន ក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២។ ក្នុងឱកាសនោះដែរ ឯកឧត្តម OM BIRLA បានពាំនាំនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីឯកឧត្តមប្រធានព្រឹទ្ធសភាឥណ្ឌា ជូនចំពោះសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងនូវសេចក្តីរីករាយដែលបានឃើញនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អលើគ្រប់វិស័យរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនឥតឈប់ឈរ។ ទំនាក់ទំនងល្អនេះស្តែងឡើងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមករវាងប្រមុខរដ្ឋប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ នៃប្រទេសទាំងពីរ និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាច្រើនគ្រប់ដណ្តប់លើវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ និងការវិនិយោគ។ ប្រទេសទាំងពីរបានគាំទ្រគ្នាទៅ

វិញទៅមកលើឆាកអន្តរជាតិជាបន្តបន្ទាប់។ កិច្ចសហប្រតិបត្តិការពហុភាគី មិនត្រឹមតែទទួលបានផលប្រយោជន៍ដល់ប្រជាជន និងប្រទេសទាំងពីរប៉ុណ្ណោះទេ ប៉ុន្តែបានរួមចំណែកដ៏សំខាន់ និងជាវិជ្ជមានដល់ការរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍរួមនៅក្នុងតំបន់ និងអន្តរជាតិ។

ក្នុងនាមប្រជាជន ព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាធារណរដ្ឋឥណ្ឌាដែលបានគាំទ្រនូវឯករាជ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងទសវត្សរ៍ទី៥០ និងជាប្រទេសដំបូងដែលទទួលស្គាល់សាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងទសវត្សរ៍ទី៨០ ហើយប្រទេសឥណ្ឌាបានបញ្ជូនកងទ័ពមួកខៀវក្រោមឆត្រអង្គការសហប្រជាជាតិមកជួយថែរក្សាសន្តិភាព នៅប្រទេសកម្ពុជាក្រោមបេសកកម្មរបស់អ៊ុនតាក់។ ជាមួយគ្នានោះ សម្តេចបានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលឥណ្ឌា ដែលបានផ្តល់ជំនួយបច្ចេកទេស និងជំនួយឥតសំណង គាំទ្រដល់វិស័យជាច្រើន ដែលបានរួមចំណែកយ៉ាងខ្លាំងក្លាធ្វើឱ្យប្រទេសកម្ពុជាបានរំដោះចេញពីភាពក្រីក្រ លើកកម្ពស់ជីវភាពរបស់ប្រជាជន និងមានការអភិវឌ្ឍដូចពេលបច្ចុប្បន្ន។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជាទទួលបានជោគជ័យក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩។ កម្ពុជាបានបើកដំណើរការពេញលេញសង្គម សេដ្ឋកិច្ច តាមគន្លងប្រក្រតីភាពថ្មី។ យោងតាមការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សេដ្ឋកិច្ចកម្ពុជានឹងកើនឡើងក្នុងអត្រា៥,៣% ក្នុងឆ្នាំ២០២២ និង៦,៥% ក្នុងឆ្នាំ២០២៣។

សម្តេចប្រធានព្រឹទ្ធសភាបានស្នើប្រទេសឥណ្ឌាពិនិត្យលទ្ធភាពឱ្យមានការហោះហើរត្រង់ ពីឥណ្ឌាមកភ្នំពេញ និងពីឥណ្ឌាមកខេត្តសៀមរាប ដែលជាគោលដៅទេសចរណ៍សុវត្ថិភាព។ ការហោះហើរត្រង់នឹងជួយជំរុញការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន និងវប្បធម៌ប្រទេសទាំងពីរ។

ទាក់ទងនឹងការអញ្ជើញសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទៅចូលរួមពិធីប្រារព្ធខួបលើកទី៣០ នៃទំនាក់ទំនងអាស៊ាន-ឥណ្ឌា សម្តេចប្រធានព្រឹទ្ធសភានឹងរៀបចំឱ្យមានឯកឧត្តមអនុប្រធានព្រឹទ្ធសភា១រូប ដើម្បីអមដំណើរសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ទៅចូលរួមក្នុងពិធីដ៏មហោឡារិកនេះ។

សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដល់រដ្ឋសភា ព្រឹទ្ធសភា និងរដ្ឋាភិបាលឥណ្ឌា ដែលបានជួយអភិវឌ្ឍន៍ធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈការផ្តល់អាហារូបករណ៍រយៈពេលខ្លី មធ្យម ទៅរៀននៅសាធារណរដ្ឋឥណ្ឌា ចំនួន២១៨នាក់ គិតចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១។ ចំពោះការរៀបចំវគ្គបណ្តុះបណ្តាលថ្មីដែលឯកឧត្តមប្រធានគណៈប្រតិភូបានលើកឡើង សម្តេចនឹងរៀបចំទាំងសមាជិកព្រឹទ្ធសភា និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីទៅចូលរួម។

សម្តេចប្រធានព្រឹទ្ធសភាបានឯកភាពចំពោះប្រសាសន៍របស់ឯកឧត្តមប្រធានគណៈប្រតិភូ ដែលលើកឡើងអំពីការផ្លាស់ប្តូរទស្សនកិច្ចរវាងសភា នៃប្រទេសទាំងពីរ ដើម្បីទៅដកបទពិសោធន៍អំពីសភាប្រជាធិបតេយ្យ និងការពង្រឹងនូវតួនាទីការទូតសភា ក្នុងការរួមចំណែកលើការថែរក្សាសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់ សន្តិសុខ និងការអភិវឌ្ឍនៅក្នុងតំបន់ និងអន្តរជាតិប្រកបដោយចីរភាព។

តាមរយៈគណៈប្រតិភូសម្តេចប្រធានព្រឹទ្ធសភា បានផ្តាំផ្ញើការសួរសុខទុក្ខដោយសេចក្តីគោរពរាប់អានជូនឯកឧត្តមប្រធានព្រឹទ្ធសភាឥណ្ឌា និងសូមអញ្ជើញឯកឧត្តមប្រធានព្រឹទ្ធសភាឥណ្ឌាដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជាតាមពេលវេលាសមស្របណាមួយ។

សម្តេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្តមប្រធានរដ្ឋសភា និងគណៈប្រតិភូ មានសុខភាពល្អ និងជោគជ័យក្នុងដំណើរទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ និងរូបភាព៖ គឹម សិទ្ធី)





*ទិដ្ឋភាពក្នុងជំនួបសវនាការ និងថតរូបអនុស្សាវរីយ*

# សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំគណៈប្រតិភូសភាកម្ពុជា បំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ





*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អញ្ជើញជួបជាមួយនឹងឯកឧត្ដម Park Byeong-seug ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ*

តបតាមការអញ្ជើញរបស់ ឯកឧត្ដម Park Byeong-seug ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូសភាកម្ពុជា បំពេញទស្សនកិច្ចជាផ្លូវការ និងមិត្តភាពនៅសាធារណរដ្ឋកូរ៉េ ដើម្បីពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន សភា និងប្រទេសទាំងពីរ ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២។ ទស្សនកិច្ចនោះ បានធ្វើឡើងស្របពេល នៃការអបអរសាទរខួបលើកទី២៥ នៃការភ្ជាប់ឡើងវិញ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។

ក្នុងអំឡុងពេល នៃដំណើរទស្សនកិច្ច សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹង៖ ឯកឧត្ដម Park Byeong-seug ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ ឯកឧត្ដម Sonh Hyuk-sang ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA), ឯកឧត្ដម Byun Jaeill សមាជិករដ្ឋសភាកូរ៉េ និងជាប្រធានក្រុមមិត្តភាពសភាកូរ៉េ-កម្ពុជា និងឯកឧត្ដម Oh Se-hoon អភិបាលរដ្ឋធានីសេអ៊ូល។ ខ្លឹមសារ និងលទ្ធផលសំខាន់ៗ នៃជំនួបមានដូចខាងក្រោម៖

**១.ជំនួបទ្វេភាគីជាមួយនឹងឯកឧត្ដម Park Byeong-seug ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២**

សម្ដេចវិបុលសេនាភក្ដី និងឯកឧត្ដមប្រធានរដ្ឋសភាកូរ៉េ បានសម្ដែងនូវអំណរសាទរខួបអនុស្សាវរីយលើកទី២៥ នៃការតភ្ជាប់ទំនាក់ទំនងការទូតឡើងវិញរវាងសាធារណរដ្ឋកូរ៉េ និងព្រះរាជាណាចក្រកម្ពុជា។ ភាគីទាំងពីរបានផ្ដល់សារសំខាន់ដល់ភារកិច្ចរបស់សភាក្នុងការលើកកម្ពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ លើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការសភាកម្ពុជា-កូរ៉េ និងបានផ្ដល់សារសំខាន់ចំពោះតួនាទីការទូតសភាដែលជួយលើកកម្ពស់ទំនាក់ទំនងក្នុងក្របខ័ណ្ឌពហុភាគី រួមចំណែកដល់សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាព។

សភា នៃប្រទេសទាំងពីរ បានឯកភាពនឹងបន្តខិតខំបង្កើនសកម្មភាពផ្លាស់ប្ដូរគណៈប្រតិភូគ្រប់កម្រិតទៅវិញទៅមក ដើម្បីឈ្វេងយល់បទពិសោធន៍លើវិស័យច្បាប់ បច្ចេកវិទ្យា នយោបាយ ការផ្លាស់ប្ដូរសមាជិកសភាវ័យក្មេង និងការបន្តគាំទ្រគ្នាទៅវិញ-ទៅមកលើកិច្ចសហប្រតិបត្តិការអន្តរសភា រួមមាន៖ សហភាពអន្តរជាតិ (IPU) វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF) មហា-សន្និបាតអន្តរសភាអាស៊ាន (AIPA) និងភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) ជាដើម។

ឯកឧត្ដមប្រធានរដ្ឋសភាកូរ៉េ បានគាំទ្រតួនាទីប្រធានប្ដូរវេននៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ របស់សភាកម្ពុជា និងចាត់តាំងគណៈប្រតិភូរដ្ឋសភាកូរ៉េមកចូលរួម។

ជាមួយគ្នានោះ ឯកឧត្ដមប្រធានរដ្ឋសភាកូរ៉េបានគាំទ្រសំណើរបស់សម្ដេចវិបុលសេនាភក្ដី ក្នុងការជួយអភិវឌ្ឍសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានសភាកម្ពុជា និងការអភិវឌ្ឍបណ្ណាល័យសភាកម្ពុជា ជាបណ្ណាល័យអេឡិចត្រូនិក។

ក្នុងនាមប្រជាជន រាជរដ្ឋាភិបាល និងសភាកម្ពុជា សម្ដេចវិបុលសេនាភក្ដី បានសម្ដែងការអរគុណចំពោះប្រជាជន និងរដ្ឋាភិបាលកូរ៉េ ដែលបានផ្ដល់ជំនួយអភិវឌ្ឍផ្លូវការដល់កម្ពុជាចាប់តាំងពីឆ្នាំ១៩៩៧ មក។ សម្ដេចវិបុលសេនាភក្ដី បានបញ្ជាក់ថា ជំនួយរបស់កូរ៉េបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច រួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្ស និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ បន្ថែមពីលើនេះ សម្ដេចវិបុលសេនាភក្ដី បានសម្ដែងការអរគុណចំពោះប្រជាជន រដ្ឋា-



*គណៈប្រតិភូសភាកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយនឹងឯកឧត្តម Park Byeong-seug ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ*

ភិបាល និងសភាកូរ៉េ ដែលបានផ្តល់ជំនួយតាមរយៈយន្តការទ្វេភាគី និងតាមយន្តការអាស៊ាន ជាសម្ភារ បរិក្ខារពេទ្យ និងថវិកាដើម្បីជួយកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដែលរួមចំណែកធ្វើឱ្យកម្ពុជាអាចបើកដំណើរការពេញលេញឡើងវិញនូវសកម្មភាពសង្គម សេដ្ឋកិច្ច តាមគន្លងប្រក្រតីភាពថ្មី។

ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េបានបញ្ជាក់ថា កូរ៉េចាត់ទុកកម្ពុជាជាមិត្តល្អ។ ក្នុងគោលនយោបាយភាគខាងត្បូងថ្មីបូក (New Southern Policy Plus) របស់សាធារណរដ្ឋកូរ៉េ កម្ពុជាជាប្រទេសអាទិភាពសម្រាប់ការផ្តល់ជំនួយអភិវឌ្ឍផ្លូវការ។ នៅឆ្នាំ២០២២ កូរ៉េបានផ្តល់ជំនួយអភិវឌ្ឍផ្លូវការចំនួន១៥០លានដុល្លារអាមេរិកដល់កម្ពុជា ដែលជាជំនួយធំបំផុតរបស់កូរ៉េនៅឆ្នាំនេះ។

ចំពោះបញ្ហាពលករ ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េ បានបញ្ជាក់ថា នឹងយកចិត្តទុកដាក់ចំពោះសំណើរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសំណើរបស់សម្តេចវិបុលសេនាភក្តី ដោយខិតខំជំរុញឱ្យស្ថាប័នពាក់ព័ន្ធពិនិត្យករណីនេះ ហើយកន្លងមកកូរ៉េបានផ្តល់អាទិភាពខ្ពស់ក្នុងការផ្តល់កូតាដល់ពលករកម្ពុជាមកធ្វើការនៅកូរ៉េ ទោះបីស្ថិតនៅក្នុងបរិបទកូវីដ-១៩ក្តី។ ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េបានចាត់ទុកថា ការទទួលយកពលករកម្ពុជាមកធ្វើការនៅកូរ៉េ ជានយោបាយឈ្នះ-ឈ្នះ ដែលមិនត្រឹមតែរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជាប៉ុណ្ណោះទេ តែក៏បានជួយជំរុញកំណើនសេដ្ឋកិច្ចកូរ៉េផងដែរ។

ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េ បានអរគុណកម្ពុជាក្នុងការជួយស្វែងរកសន្តិភាពនៅឧបទ្វីបកូរ៉េ និងស្នើសុំកម្ពុជាបន្តគាំទ្រលើការស្វែងរកសន្តិភាពនៅឧបទ្វីបកូរ៉េ និងការគាំទ្រទីក្រុងប៊ូសានធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ World Expo ២០៣០។ ជាការឆ្លើយតប សម្តេចវិបុលសេនាភក្តី បានបញ្ជាក់នូវគោលជំហរបន្តគាំទ្រកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ដែលមានស្រាប់ និងនាពេលអនាគត។

**២.ជំនួបពិភាក្សាការងារជាមួយនឹងឯកឧត្តម Sonh Hyuk-sang ប្រធានទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) នាព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២**

ក្នុងជំនួបពិភាក្សាការងារនោះ សម្តេចវិបុលសេនាភក្តី និងឯកឧត្តម Sonh Hyuk-sang ប្រធាន KOICA បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាង KOICA ជាមួយនឹងរាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់របស់កម្ពុជាក្នុងការអនុវត្ត





*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម Sonh Hyuk-sang ប្រធាន KOICA*





*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អញ្ជើញជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម Oh Se-hoon អភិបាលរដ្ឋធានីសេអ៊ូល*

គម្រោងសហប្រតិបត្តិការនានានៅកម្ពុជា។ ឯកឧត្តមប្រធាន KOICA បានជម្រាបជូនសម្ដេចវិបុលសេនាភក្ដីថា កម្ពុជាគឺជាប្រទេសដៃគូដ៏សំខាន់របស់កូរ៉េជាប់ចំណាត់ថ្នាក់កំពូលទី៣ នៃការគាំទ្រការអភិវឌ្ឍរបស់ KOICA ក្នុងឆ្នាំ២០២២ ដែលទទួលបានជំនួយឥតសំណងចំនួនប្រមាណ៣០លានដុល្លារអាមេរិក។

សម្ដេចវិបុលសេនាភក្ដី បានបង្ហាញការគាំទ្រចំពោះកម្មវិធីនៃកិច្ចសហប្រតិបត្តិការរបស់ KOICA សម្រាប់កម្ពុជាលើវិស័យអាទិភាពចំនួន៤ រួមមាន៖ (១) ការគ្រប់គ្រងធនធានទឹក និងសុខភាពសាធារណៈ (២) ការអប់រំ (៣) កសិកម្ម និងអភិវឌ្ឍន៍ជនបទ និង(៤) ការដឹកជញ្ជូន។ គម្រោងអាទិភាពទាំង៤ បានឆ្លើយតបទៅនឹងសេចក្ដីត្រូវការជាក់ស្ដែងសម្រាប់ការអភិវឌ្ឍកម្ពុជា។

សម្ដេចវិបុលសេនាភក្ដី បានថ្លែងអំណរគុណដល់ជំនួយរបស់រដ្ឋាភិបាលសធារណរដ្ឋកូរ៉េផ្ដល់ឱ្យតាមរយៈ KOICA ដែលបានរួមចំណែកគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួយកសាងស្ដារអភិវឌ្ឍសង្គម សេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ព្រមទាំងបានថ្លែងអំណរគុណដល់ KOICA ដែលបានជួយគាំទ្រដល់គម្រោងវិស័យសុខាភិបាលនានា ក៏ដូចជា៖ ការជួយគាំទ្រលើការអភិវឌ្ឍធនធានមនុស្ស តាមរយៈវគ្គបណ្ដុះបណ្ដាល និងការផ្ដល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតជាច្រើននាក់ ដែលក្នុងនោះមានរួមទាំងមន្ត្រី នៃអគ្គលេខាធិការព្រឹទ្ធសភាចំនួន៤៧រូបផងដែរ។

ក្នុងអំឡុងនៃជំនួបនោះផងដែរ គណៈប្រតិភូសភាកម្ពុជាក៏បានលើកឡើងនូវសំណូមពរដល់ KOICA ពិចារណាជួយគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ដែលជាវិស័យមានសក្ដានុពល និងជួយគាំទ្រការអភិវឌ្ឍជនបទនៅកម្ពុជាតាមរយៈគម្រោងភូមិតេជោ១០០ដែលស្របទៅនឹងទស្សនសេម៉ាអ៊ុនដុង។ ឯកឧត្តម Sonh Hyuk-sang បានឆ្លើយតបគាំទ្រលើសំណូមពរលើវិស័យទាំងពីរ ដោយបញ្ជាក់ថា KOICA កំពុងនិងបន្តធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធលើគម្រោងកិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដែលត្រូវបានចាត់ទុកជាអាទិភាព។

ជាមួយគ្នានោះ ឯកឧត្តមប្រធាន KOICA បានយល់ព្រមពិនិត្យលទ្ធភាពក្នុងការពង្រីកថែមចំនួនមន្ទីរពេទ្យឯកទេសកុមារ និងស្ត្រីឱ្យបានច្រើនបន្ថែមទៀតទៅដល់ជនបទនៅកម្ពុជា និងជួយបង្កើនចំនួនមន្ត្រីរាជការ សិស្ស និស្សិតចូលរួមវគ្គសិក្សារយៈពេលខ្លី មធ្យម និងអាហារូបករណ៍ថ្នាក់អនុបណ្ឌិត និងបណ្ឌិតបន្ថែមទៀត ព្រមទាំងជួយបណ្ដុះបណ្ដាលសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានសភាកម្ពុជា។

ចំពោះការជួយគាំទ្រសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានសភាកម្ពុជា ភាគីសភាកម្ពុជាបានស្នើសុំធ្វើការជាមួយនឹងKOICA ប្រចាំកម្ពុជា ដើម្បីសិក្សាកំណត់ និងលើកគម្រោងសហប្រតិបត្តិការអភិវឌ្ឍន៍សមត្ថភាពសម្រាប់មន្ត្រីសភាកម្ពុជាជាជំហានដំបូង។

សម្ដេចវិបុលសេនាភក្ដី ក៏បានស្នើផងដែរឱ្យឯកឧត្តមប្រធាន KOICA ជួយពិនិត្យ និងគាំទ្រលើសំណើគម្រោងកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងដាក់ជូនរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ដើម្បីអភិវឌ្ឍវិស័យសំខាន់ៗ សម្រាប់ពេលខាងមុខ។

**៣.ជំនួបពិភាក្សាការងារជាមួយនឹងឯកឧត្តម Byun Jaeill ប្រធានក្រុមមិត្តភាពសភាកូរ៉េ-កម្ពុជា នារសៀលថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២**

សម្ដេចវិបុលសេនាភក្ដី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមមិត្តភាពសភាកូរ៉េ-កម្ពុជា ក្នុងការតភ្ជាប់ និងបង្កើនទំនាក់ទំនងសភាទាំងពីរកូរ៉េ-កម្ពុជា។ ឯកឧត្តម Byun Jaeill សមាជិករដ្ឋសភាកូរ៉េ និងជាប្រធានក្រុមមិត្តភាពសភាកូរ៉េ-កម្ពុជា បានលើកឡើងនូវភាពចាំបាច់ និងពេលវេលាស័ក្ដិសម ដែលសម្ដេចវិបុលសេនាភក្ដីបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ នៅពេលដែលកូរ៉េកំពុងគ្រប់គ្រងវិបត្តិកូវីដបានមួយភាគ




*ឯកឧត្តម Byun Jaeill អញ្ជើញសម្តេចវិបុលសេនាភក្តី សាយ ឈុំ ពិសាអាហារថ្ងៃត្រង់ និងពិភាក្សាការងារ*

ធំបានល្អ។

ភាគីទាំងពីរបានប្តេជ្ញាពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងក្រុមមិត្តភាពសភាកូរ៉េ-កម្ពុជា ឱ្យកាន់តែស្អិតរមួត តាមរយៈសកម្មភាពនៃការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមក និងជួយជំរុញការផ្លាស់ប្តូរពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរឱ្យកាន់តែច្រើន និងទូលំទូលាយបន្ថែមទៀត។

ឯកឧត្តម Byun Jaeill ក៏បានស្វាគមន៍ចំពោះសំណើរបស់ភាគីកម្ពុជា ក្នុងកិច្ចប្រជុំជាមួយនឹងឯកឧត្តមប្រធាន KOICA ក្នុងការគាំទ្រនូវការកសាងផែនការមេ នៃគម្រោងគំរូអភិវឌ្ឍន៍ជនបទ ដែលមានឈ្មោះថាគម្រោងភូមិតេជោ ១០០។

**៤.ជំនួបពិភាក្សាការងារជាមួយនឹងឯកឧត្តម អភិបាលរដ្ឋធានីសេអ៊ូល នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២**

ក្នុងអំឡុងពេល នៃទស្សនកិច្ចផ្លូវការនោះ សម្តេចវិបុលសេនាភក្តី ក៏បានដឹកនាំគណៈប្រតិភូសភាកម្ពុជាជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម Oh Se-hoon អភិបាលរដ្ឋធានីសេអ៊ូល ក្នុងនោះភាគីទាំងពីរបានពិភាក្សា និងផ្លាស់ប្តូរយោបល់អំពីការអភិវឌ្ឍ នៃរដ្ឋធានីសេអ៊ូល និងរាជធានីភ្នំពេញ និងលទ្ធភាពនៃការជំរុញកិច្ចសហប្រតិបត្តិការរវាងគ្នាទៅវិញទៅមក។

សម្តេចវិបុលសេនាភក្តី បានកោតសរសើរពីការរីកចម្រើនដ៏អស្ចារ្យរបស់ទីក្រុងសេអ៊ូលដែលចាត់ទុកជាទីក្រុងវៃឆ្លាត និងបានជម្រាបឯកឧត្តម Oh Se-hoon អភិបាលរដ្ឋធានីសេអ៊ូល អំពីការផ្លាស់ប្តូររបស់ទីក្រុងភ្នំពេញ ពីក្រុងដែលគ្មានមនុស្សរស់នៅ និងបានរងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធយ៉ាងធ្ងន់ធ្ងរ និងស្ទើរតែទាំងស្រុង ក្នុងសម័យរបបប្រល័យពូជសាសន៍ ទៅជារាជធានីត្រូវបានស្តារ និងអភិវឌ្ឍន៍ឡើងវិញ។

ក្នុងឱកាសនៃជំនួបពិភាក្សាខាងលើនោះ ឯកឧត្តមអភិបាលក៏បានស្វាមគមន៍ និងយកចិត្តទុកដាក់ចំពោះសំណើរបស់សម្តេចវិបុលសេនាភក្តី (១) ការពិនិត្យលទ្ធភាពចងសម្ព័ន្ធមេត្រីភាពរវាងរាជធានីភ្នំពេញនិងទីក្រុងសេអ៊ូល និង(២) ការជួយបណ្តុះបណ្តាលធនធានមនុស្ស និងជួយផ្ទេរបច្ចេកទេស ចំណេះដឹងជំនាញ ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍទីក្រុង។

ក្រៅពីជំនួបខាងលើ នារាត្រីថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី ក៏បានជួបសំណេះសំណាលសាកសួរសុខទុក្ខប្រកបដោយភាពកក់ក្តៅជាភាតរៈជាមួយនឹងមន្ត្រីស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅសាធារណរដ្ឋកូរ៉េ ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

(អត្ថបទ៖ ទេព មករា)



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញថតរូបអនុស្សាវរីយជាមួយនឹងឯកឧត្តម Byun Jaeill ប្រធានក្រុមមិត្តភាពសភាកូរ៉េ-កម្ពុជា*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញប្រារព្ធពិធីបង្សុកូល ដើម្បីឧទ្ទិសកុសល ជូនមាតា បិតា ញាតិទាំង៧សន្តាន នៅភូមិកណ្ដាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ គ.ស.២០២២។



❈នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បានអញ្ជើញប្រារព្ធពិធីបង្សុកូល ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធមាតា បិតា ញាតិទាំង៧សន្តាន នៅវត្តនាគវ័ន្ត ដែលស្ថិតនៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បានអញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសក **គង់ ខាត់** និងដួងវិញ្ញាណក្ខន្ធមាតា បិតា ញាតិទាំង៧សន្តាន នៅវត្តសុវណ្ណគិរី (ហៅវត្តជើងឆ្នុក) ស្ថិតក្នុងភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម។



❈នារសៀលថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍ពីទីក្រុងប៉េកាំង ប្រទេសចិនរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រីនរោត្តម **មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសពមហាឧបាសិកា **តាន់ រ៉ាយ** ម្ដាយបង្កើតរបស់ឯកឧត្តម **កៅ ខុនដារ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលបានទទួលមរណភាពក្នុងជន្មាយុ៩០ឆ្នាំ ដោយជរាពាធ នៅភូមិវាល ឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ។



❈នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំខណ្ឌ និងសមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ទាំង៦ នៃខណ្ឌសែនសុខ រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំខណ្ឌ និងសមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ទាំង៥ នៃខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំខណ្ឌ និងសមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ទាំង១០ នៃខណ្ឌទួលគោក នៅភោជនីយដ្ឋានឡាក់គីស្តារ ស្ថិតក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី បានអញ្ជើញនាំយកទេយ្យទានប្រគេនព្រះសង្ឃ នៅវត្តប្រាំបីមុំ ស្ថិតក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។



❈នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុំ ភា** អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ដើម្បីប្រោះព្រំសុំនូវសេចក្ដីសុខ និងសិរីសួស្ដី ជូនចំពោះថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យបញ្ចុះសពមហាឧបាសិកា **តាន់ រ៉ាយ** ម្ដាយរបស់ឯកឧត្តម **កៅ ខុនដារ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ៕



# គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥សំណេះសំណាលថ្នាក់ដឹកនាំស្រុក និងក្រុមប្រឹក្សាឃុំក្នុងស្រុកត្រាំកក់



*គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុក និងក្រុមប្រឹក្សាឃុំក្នុងស្រុកត្រាំកក់*

នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ គណៈកម្មការទី១ព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការ និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដឹកនាំដោយឯកឧត្តម **ខៀវ មុត** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំស្រុក និងក្រុមប្រឹក្សាឃុំ ជំទប់ទី១ ជំទប់ទី២ នៅស្រុកត្រាំកក់ ខេត្តតាកែវ សរុបចំនួន៥០នាក់ នៅសាលប្រជុំសាលាស្រុកត្រាំកក់ ខេត្តតាកែវ។

ពិធីសំណេះសំណាលនោះរៀបចំឡើងដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានអំពី ការអនុវត្តការងាររបស់ស្រុក និងឃុំ បញ្ហាប្រឈម និងសំណូមពរនានា ព្រមទាំងការត្រៀមលក្ខណៈក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។

ក្នុងឱកាសនោះ លោក **ភៅ វឌ្ឍសែល** អភិបាលស្រុកត្រាំកក់ បានធ្វើសេចក្តីរាយការណ៍អំពីការងារទូទៅក្នុងរដ្ឋបាល ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការងារសេដ្ឋកិច្ច ជីវភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។

ក្នុងនាមគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្តម **យ៉ង់ សែម** បានអំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងស្រុកត្រាំកក់ត្រូវត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ចំពោះការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ដើម្បីធ្វើយ៉ាងណាឱ្យការបោះឆ្នោតនោះប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវ យុត្តិធម៌ សេរី និងគ្មានអំពើហិង្សា ព្រមទាំងដំណើរការទៅដោយរលូន និងគ្មានការបង្ខិតបង្ខំ។

ឯកឧត្តម **យ៉ង់ សែម** បានក្រើនរំលឹកដល់អាជ្ញាធរទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ចំពោះជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការរបស់រាជរដ្ឋាភិបាល គឺ ៣កុំ និង៣ការពារ។

ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ឯកឧត្តម **ខៀវ មុត** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំបំពេញភារកិច្ចរបស់អាជ្ញាធរមូលដ្ឋានក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ។ ឯកឧត្តម **ខៀវ មុត** បានផ្តល់អនុសាសន៍ដល់អាជ្ញាធរទាំងអស់ ត្រូវរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង ផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើងថែមទៀត រួសរាន់ដោះស្រាយរាល់បញ្ហាប្រឈម ការលំបាក ការខ្វះខាតរបស់មូលដ្ឋានឱ្យបានឆាប់រហ័ស ប្រកបដោយតម្លាភាពនិងយុត្តិធម៌។

ក្រៅពីចុះជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំស្រុក ឃុំ គណៈប្រតិភូបានអញ្ជើញចូលថ្វាយបង្គំ និងនាំយកនូវទេយ្យទាន គ្រឿងឧបភោគ បរិភោគរួមមាន៖ ស្លាដក់ចំនួន៤ អង្ករ៥០គីឡូក្រាម មី២កេស ត្រីខកំប៉ុង២យួរ ទឹកផ្លែឈើ២កេស ទឹកត្រី២យួរ ទឹកស៊ីអ៊ីវ២យួរ ទឹកបរិសុទ្ធ២កេស ព្រមទាំងបច្ច័យមួយចំនួន ប្រគេនព្រះសង្ឃគង់នៅក្នុងវត្តអង្គតាសោម ព្រមទាំងជួបសំណេះសំណាលសួរសុខទុក្ខ និងចែកអំណោយជូនបងប្អូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន១០គ្រួសារ ដោយក្នុងមួយគ្រួសារៗទទួលបានមី១កេស ត្រីខកំប៉ុង១យួរ ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ និងថវិកាមួយចំនួន ស្ថិតក្នុងស្រុកត្រាំកក់ ខេត្តតាកែវ៕

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

# គណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាលក្រុមប្រឹក្សាឃុំទាំង៥ នៃស្រុករតនមណ្ឌល ខេត្តបាត់ដំបង



គណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាលក្រុមប្រឹក្សាឃុំទាំង៥ នៃស្រុករតនមណ្ឌល

កាលព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការ បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំទាំង៥ នៃស្រុករតនមណ្ឌល ខេត្តបាត់ដំបង សរុប៦៩នាក់។

ពិធីសំណេះសំណាលនោះរៀបចំឡើងដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មាននានាពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ស្រុក ឃុំ រួមមាន៖ **១**-រដ្ឋបាលឃុំមានផែនការសកម្មភាពអ្វីខ្លះ ដើម្បីបង្កើតជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ។ **២**-ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព តើមានបញ្ហាប្រឈមអ្វីខ្លះ។ **៣**-មណ្ឌលបណ្ដុះបណ្ដាលកម្រិតវប្បធម៌ក្នុងស្រុករតនមណ្ឌលមានប៉ុន្មានកន្លែង (សហគមន៍ បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ)។ **៤**-ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ អាជីវកម្មចម្បងអ្វីខ្លះ មុខរបរអ្វីខ្លះ ប្រភេទចំណូលសំខាន់របស់ប្រជាពលរដ្ឋក្នុងឃុំ ស្រុក។ **៥**-ការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋក្នុងឃុំ ទៅចូលរួមបោះឆ្នោតឱ្យបានគ្រប់ៗគ្នា។ **៦**-បន្តផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋឱ្យចូលរួមទប់ស្កាត់ជំងឺកូវីដ-១៩។



ទិដ្ឋភាពក្នុងពិធីសំណេះសំណាល

**៧**-ស្ដាប់បញ្ហាប្រឈម និងសំណូមពរជុំវិញការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ ស្រុក។ **៨**-ការប្រមូលផ្ដុំវិធានការសរុប មធ្យោបាយសរុប និងកម្លាំងសរុប ឆ្ពោះទៅធានាភាពជោគជ័យក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

បន្ទាប់ពីលោក **គួយ ចណ្ណា** អភិបាលស្រុករតនមណ្ឌល និងក្រុមប្រឹក្សាឃុំទាំង៥ នៃស្រុករតនមណ្ឌលឡើងធ្វើសេចក្ដីរាយការណ៍អំពី វឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណូមពររួចមក ឯកឧត្តម **យ៉ង់ សែម** បានថ្លែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ និងអាជ្ញាធរពាក់ព័ន្ធក្នុងស្រុករតនមណ្ឌល ដែលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនសម្រេចបានលទ្ធផល សមិទ្ធផលយ៉ាងច្រើន និងមានការអភិវឌ្ឍសេដ្ឋកិច្ច សង្គមជាលំដាប់។

ឯកឧត្តម **យ៉ង់ សែម** បានជំរុញឱ្យថ្នាក់ដឹកនាំស្រុក និងក្រុមប្រឹក្សាឃុំ អាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបន្តខិតខំរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង ស្របតាមគោលការណ៍សមូហភាព មានស្មារតីទទួលខុសត្រូវខ្ពស់ ហើយចេះរក្សាសមិទ្ធផលចាស់ និងបង្កើនសមិទ្ធផលថ្មីៗ ព្រមទាំងត្រូវយកចិត្តទុកដាក់ដល់មន្ត្រីមូលដ្ឋានចាស់ជរា ជានិវត្តជនដែលជាមេឃុំ ចៅសង្កាត់ ស្មៀន មេប៉ុស្តិ៍ និងប្រធានភូមិ ដែលមានបទពិសោធន៍ក្នុងការដឹកនាំ ព្រមទាំងខិតខំធ្វើអំពើល្អ ស្រឡាញ់ប្រជាជន បម្រើប្រជាជន ផ្ដល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ ចូលរួមដោះស្រាយរាល់បញ្ហាប្រឈម ការលំបាក ការខ្វះខាតរបស់មូលដ្ឋានឱ្យបានឆាប់រហ័ស ដោយតម្លាភាព និងមានយុត្តិធម៌។

ក្រៅពីចុះជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំស្រុក និងឃុំ គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញថ្វាយបង្គំព្រះសង្ឃ ព្រមទាំងនាំយកទេយ្យវត្ថុប្រគេនដល់ព្រះសង្ឃនៅវត្តត្រែង ស្ថិតនៅឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដោយប្រគេនទេយ្យវត្ថុរួមមាន៖ អង្ករ៥០គីឡូក្រាម មី២កេស ត្រីខកំប៉ុង២យួរ ទឹកផ្លែឈើ២កេស ទឹកត្រី២យួរ ទឹកស៊ីអ៊ីវ២យួរ ទឹកសុទ្ធ២កេស និងបច្ច័យមួយចំនួន ព្រមទាំងចែកអំណោយជូនដល់បងប្អូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន៥គ្រួសារ ដោយក្នុងមួយគ្រួសារៗទទួលបាន៖ មី១កេស ត្រីខកំប៉ុង១យួរ ទឹកត្រី១យួរ និងថវិកាមួយចំនួនផងដែរ៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)

# គណៈកម្មការទី២ព្រឹទ្ធសភាសំណេះសំណាល ក្រុមប្រឹក្សាឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ



*ឯកឧត្តម ជា ជេដ្ឋ និងឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី*

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) ដឹកនាំដោយឯកឧត្តម **ជា ជេដ្ឋ** ប្រធានគណៈកម្មការ ដោយមានការចូលរួមពីឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងថ្នាក់ដឹកនាំក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប ដើម្បីឈ្វេងយល់ប្រមូលព័ត៌មានស្ដីពី“ការអភិវឌ្ឍឃុំកែវផុសរយៈពេល៥ឆ្នាំ និងទស្សនកិច្ចតំបន់អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ម៉ុង ឫទ្ធី” នៅសាលប្រជុំភូមិគ្រឹះ ឧកញ៉ា **ម៉ុង ឫទ្ធី** កាលពីថ្ងៃទី៩ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។

ពិធីសំណេះសំណាលនោះរៀបចំឡើងដើម្បីឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតលើ៖ ១-លទ្ធផលនៃការអភិវឌ្ឍមូលដ្ឋានឃុំកែវផុសរយៈពេល៥ឆ្នាំ។ ២-ការអនុវត្តថវិកាថ្នាក់ក្រោមជាតិ (ទទួល-ទូទាត់) ការធ្វើគម្រោងអភិវឌ្ឍមូលដ្ឋាន ការប្រើប្រាស់មូលនិធិសង្កាត់ (វដ្តទេយ្យបុរេប្រទាន) និងបញ្ហាប្រឈម។ ៣-សមត្ថភាពក្នុងការកសាង និងអនុវត្តគម្រោងអភិវឌ្ឍន៍ថ្នាក់ឃុំ។ ៤-ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការផ្ដល់សេវាសាធារណៈ។ ៥-ការចូលរួមអភិវឌ្ឍមូលដ្ឋានរបស់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ ៦-វឌ្ឍនភាព នៃការអភិវឌ្ឍតំបន់អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ម៉ុង ឫទ្ធី។

បន្ទាប់ពីអាជ្ញាធរឃុំកែវផុស និងថ្នាក់ដឹកនាំក្រុមហ៊ុន ម៉ុង ឫទ្ធី ឡើងធ្វើសេចក្ដីរាយការណ៍រួចមក ឯកឧត្តម **ជា ជេដ្ឋ** បានថ្លែងនូវការកោតសរសើរចំពោះលទ្ធផលដ៏ល្អប្រសើរក្នុងការអនុវត្តការងារនៅក្នុងឃុំកែវផុស។ ដោយមានការចូលរួមពីក្រុមហ៊ុន ម៉ុង ឫទ្ធី បានជួយលើកកម្ពស់ជីវភាពប្រជាជន កសាងហេដ្ឋារចនាសម្ព័ន្ធព្រមទាំងផ្នែកសង្គមកិច្ច វប្បធម៌ សុខាភិបាល។ល។ សមិទ្ធផលទាំងអស់នេះ បានធ្វើឱ្យឃុំកែវផុសមានការប្រែមុខមាត់ថ្មី។

ឯកឧត្តម **ជា ជេដ្ឋ** បានផ្ដាំផ្ញើដល់ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ មានទំនុកចិត្ត និងមានភាពជឿជាក់ ព្រមទាំងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពដើម្បីការពារផលប្រយោជន៍ និងសុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសត្រូវត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ ដើម្បីចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខ។

ក្រោយពីជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរ គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ជា ជេដ្ឋ** ប្រធានគណៈកម្មការ រួមដំណើរដោយឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ បានអញ្ជើញទស្សនកិច្ចរោងចក្រផលិតចំណីសត្វ កសិដ្ឋានចិញ្ចឹមជ្រូក ចម្ការដូងប្រេង អាងចម្រោះទឹកស្អាត រោងចក្រអគ្គិសនី ចម្ការកៅស៊ូ និងរោងចក្រកែច្នៃកៅស៊ូក្រែប ជាតំបន់អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ម៉ុង ឫទ្ធី ស្ថិតនៅក្នុងឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ៕

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

# គណៈកម្មការទី៣ព្រឹទ្ធសភាឈ្វេងយល់អំពីការអនុវត្តច្បាប់ និងស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកំពង់ស្ពឺ



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី អញ្ជើញជួបពិភាក្សាការងារ ជាមួយនឹងអាជ្ញាធរខេត្តកំពង់ស្ពឺ*

នាព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន នៃព្រឹទ្ធសភា (គណៈកម្មការទី៣) ដឹកនាំដោយឯកឧត្តម បណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សា ការងារជាមួយនឹងអាជ្ញាធរខេត្តកំពង់ស្ពឺ មន្ទីរជំនាញពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រធានសហគមន៍កសិកម្ម ដឹកនាំ ដោយឯកឧត្តម **វ៉ី សំណាង** អភិបាល នៃគណៈអភិបាលខេត្ត កំពង់ស្ពឺ ដើម្បីឈ្វេងយល់ និងស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យ ជាសមត្ថកិច្ចរបស់គណៈកម្មការ បញ្ហាប្រឈម និងសំណូមពរ នានារបស់ខេត្ត នៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ។

ក្នុងឱកាសជួបពិភាក្សាការងារនោះ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** បានមានប្រសាសន៍ពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ ដឹកនាំព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ កងកម្លាំង ប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ក្នុងខេត្តកំពង់ស្ពឺ។ ឯកឧត្តមបាន បញ្ជាក់អំពីគោលបំណងរបស់គណៈកម្មការដែលចុះមកខេត្ត កំពង់ស្ពឺ គឺដើម្បីឈ្វេងយល់៖ **ទី១**-ការអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាល និងវឌ្ឍនភាពការងាររបស់ខេត្ត។ **ទី២**-បញ្ហា



*ឯកឧត្តមឧកញ៉ា ម៉ុង ឫទ្ធី ប្រគល់វត្ថុអនុស្សាវរីយ៍ដល់អាជ្ញាធរខេត្តកំពង់ស្ពឺ*

ប្រឈមនិងសំណូមពររបស់ឃុំ-សង្កាត់ ពាក់ព័ន្ធនឹងវិស័យកសិ-កម្ម ធនធានទឹក អភិវឌ្ឍន៍ជនបទ បរិស្ថាន និងការវិនិយោគ។ **ទី៣**-ការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធ ទៅនឹងការពង្រឹងវិស័យនីតិរដ្ឋនៅកម្ពុជា។ **ទី៤**-ការឈ្វេងយល់ អំពីប្រតិបត្តិការវិស័យឯកជន និងបញ្ហាប្រឈម។ **ទី៥**-ការ ឈ្វេងយល់អំពី ការគ្រប់គ្រង និងចលនាសហគមន៍កសិកម្ម។ **ទី៦**-ការងារ និងលទ្ធផលតាមវិស័យដែលពាក់ព័ន្ធទៅនឹងសមត្ថ-កិច្ចរបស់គណៈកម្មការ ដូចជា៖ ផែនការ វិនិយោគ កសិកម្ម ធនធានទឹក អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ព្រមទាំងបញ្ហាប្រឈម និងសំណូមពរនានា ដែលខេត្តបានជួបនាពេលកន្លងទៅ និង ពេលបច្ចុប្បន្ន។

ក្នុងឱកាសនោះ ឯកឧត្តម **វ៉ី សំណាង** អភិបាល នៃគណៈ-អភិបាលខេត្តកំពង់ស្ពឺ និងមន្ទីរពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រធានសហគមន៍កសិកម្ម បានធ្វើសេចក្ដីរាយការណ៍អំពី វឌ្ឍនភាពការងារ ការងារសន្តិសុខសណ្ដាប់ធ្នាប់ ការផ្ដល់សេវា សាធារណៈ ការងារសង្គម វិស័យផែនការវិនិយោគ កសិកម្ម ធនធានទឹក អភិវឌ្ឍន៍ជនបទ បរិស្ថាន និងការកសាងហេដ្ឋា-រចនាសម្ព័ន្ធ និងបញ្ហាប្រឈមមួយចំនួនដែលអាជ្ញាធរខេត្តបាន ជួបប្រទះ នាពេលកន្លងទៅ។

ក្នុងនាមគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធ ដែលខិតខំបំពេញការងារក្នុង ការផ្ដល់សេវាជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរព្រមទាំងធ្វើ ឱ្យខេត្តមានការរីកចម្រើន។ ចំពោះបញ្ហាប្រឈមដែលអាជ្ញាធរ ខេត្ត និងមន្ទីរពាក់ព័ន្ធដែលបានលើកឡើង គឺទាមទារឱ្យអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវតែចូលរួមដោះស្រាយជាមួយគ្នា ដើម្បីឱ្យមានការអភិវឌ្ឍកាន់តែល្អប្រសើរឡើង។ ដោយឡែក ចំពោះសំណូមពរនានាដែលបានលើកឡើង គណៈប្រតិភូគណៈ-កម្មការទី៣ព្រឹទ្ធសភា នឹងរាយការណ៍ជូនគណៈកម្មាធិការអចិ-ន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីលើកជាអនុសាសន៍ដល់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ចាត់វិធានការដោះស្រាយតាមលទ្ធភាពដែលអាចធ្វើ ទៅបាន។

ក្នុងដំណើរបេសកកម្មនោះ គណៈប្រតិភូក៏បានអញ្ជើញទៅ ទស្សនកិច្ចឈ្វេងយល់អំពីវឌ្ឍនភាព និងការអភិវឌ្ឍលើវិស័យ នានា នៅក្នុងតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ស្ថិតក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)

# គណៈកម្មការទី៥ព្រឹទ្ធសភាអញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុនសែន ខេត្តពោធិ៍សាត់ សហគមន៍តម្បាញ មជ្ឈមណ្ឌលបកគ្រាប់ស្វាយចន្ទី និងសហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ





*គណៈកម្មការទី៥ព្រឹទ្ធសភាអញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុនសែន ខេត្តពោធិ៍សាត់ និងសហគមន៍តម្បាញ ខេត្តកំពង់ធំ*

ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយលោកជំទាវ **ទី បូរ៉ាសុី** ប្រធានគណៈកម្មការ បានអញ្ជើញបំពេញទស្សនកិច្ចឈ្វេងយល់អំពី តម្បាញ ហូល ផាមួង ក្រមា មួក កន្ទេល កញ្ជើ ល្អី និងផលិតផលកែច្នៃដោយដៃ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុនរ៉ានី ហ៊ុនសែន ខេត្តពោធិ៍សាត់ សហគមន៍តម្បាញ មជ្ឈមណ្ឌលបកគ្រាប់ស្វាយចន្ទី និងសហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ ស្ថិតក្នុងភូមិសំបូរ ឃុំសំបូរណ៍ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

មជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុនសែន ខេត្តពោធិ៍សាត់ ចាប់បដិសន្ធិឡើងនៅខែមិថុនា ឆ្នាំ១៩៩៦ ដោយផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រីមេម៉ាយក្រីក្រ ក្មេងស្រី និងយុវវ័យ សរុបចំនួន១០០នាក់ក្នុងមួយឆ្នាំលើជំនាញ៖ កាត់ដេរ តម្បាញក្រមាដោយប្រើល័ក្ខធម្មជាតិសំពត់ និងសូត្រ តម្បាញកន្ទេលរពាក់ តម្បាញកន្ទេលកក់ សម្អាងការ ចម្លាក់ថ្មកែវ កុំព្យូទ័រ និងកែច្នៃម្ហូបអាហារ។

ផលិតផលដែលមជ្ឈមណ្ឌលផលិតបាន មានលក់នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ព្រមទាំងនៅក្រៅប្រទេស តាមរយៈការចូលរួមតាំងពិព័រណ៍។

ដោយឡែកមជ្ឈមណ្ឌលបកគ្រាប់ស្វាយចន្ទី និងសហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ គឺជារោងចក្រកែច្នៃក្នុងស្រុកមួយដែលនាំចេញគ្រាប់ស្វាយចន្ទីទៅកាន់ទីផ្សារប្រទេសជប៉ុន។

ជាង២ឆ្នាំកន្លងទៅ សិប្បកម្មកែច្នៃស្វាយចន្ទីបាននាំចេញផលិតផលស្វាយចន្ទីពាក់កណ្តាលសម្រេចទៅទីផ្សារប្រទេសជប៉ុនបានជិត២០តោន។ យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញថាក្នុងឆ្នាំ២០២១ ប្រទេសកម្ពុជានាំចេញគ្រាប់ស្វាយចន្ទីបានជិត៩៤ម៉ឺនតោន ដែលកើនរហូតដល់៣២៨,៣៤ភាគរយ ធៀបនឹងឆ្នាំ២០២០។ ការនាំចេញនេះ មានលើសពី៥០ភាគរយ គឺជាការនាំចេញគ្រាប់ស្រស់ ដោយមិនទាន់កែច្នៃ។

ក្នុងឱកាសបំពេញទស្សនកិច្ចដោយឡែក លោកជំទាវ **ទី បូរ៉ាសុី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះស្នាដៃ ផលិតផលនានាដែលមជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុនសែនខេត្តពោធិ៍សាត់ សហគមន៍តម្បាញ និងមជ្ឈមណ្ឌលបកគ្រាប់ស្វាយចន្ទី និងសហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ ដែលបានខិតខំច្នៃប្រឌិតផលិតបាននូវផលិតផលជាច្រើន ដែលបង្ហាញអំពីអត្តសញ្ញាណជាតិ ព្រមទាំងចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រជាមួយនឹងរាជរដ្ឋាភិបាល តាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនបងប្អូនប្រជាពលរដ្ឋ៕

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)

# គណៈកម្មការទី៥ព្រឹទ្ធសភាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន នៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត




*គណៈកម្មការទី៥ព្រឹទ្ធសភាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន នៅខេត្តកោះកុង*

ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយលោកជំទាវ **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន នៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត។

ក្នុងឱកាសជួបពិភាក្សាជាមួយនឹងអាជ្ញាធរខេត្តនីមួយៗ លោកជំទាវ **ទី ម៉ូរ៉ាស៊ី** បានពាំនាំនូវប្រសាសន៍សាកសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់នៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត។ លោកជំទាវបានបញ្ជាក់អំពីគោលបំណងរបស់គណៈប្រតិភូ ដែលបំពេញបេសកកម្ម គឺដើម្បីឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅលើវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការដូចជា៖ ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនបរទេស ការផ្ដល់ប័ណ្ណការងារ ការត្រួតពិនិត្យប័ណ្ណ ឬសៀវភៅការងាររបស់ជនបរទេសដែលកំពុងធ្វើការនៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន ការអនុវត្តច្បាប់ស្ដីពី របបសារព័ត៌មាន ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ខេត្តដូចជា វិទ្យុ ទូរទស្សន៍ កាសែត ព័ត៌មានអនឡាញ ទស្សនាវដ្ដី ព្រមទាំងការប្រមូលព័ត៌មានអំពីប្រសិទ្ធភាពនៃការអនុវត្តការងារ លទ្ធផលការងារ បញ្ហាប្រឈម និងសំណូមពរនានារបស់ខេត្ត។

បន្ទាប់ពីបានស្ដាប់សេចក្ដីរាយការណ៍របស់អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធក្នុងខេត្តទាំងបី ក្នុងជំនួបផ្សេងគ្នារួចមក លោកជំទាវ **ទី ម៉ូរ៉ាស៊ី** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនដែលធ្វើឱ្យខេត្តមានការរីកចម្រើន។ លោកជំទាវបានសម្ដែងនូវសេចក្ដីរីករាយដែលមើលឃើញខេត្តទាំងបីមានការអភិវឌ្ឍ និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

លោកជំទាវ **ទី ម៉ូរ៉ាស៊ី** បានជំរុញឱ្យអាជ្ញាធរខេត្ត និងមន្ទីរទាំងអស់ ក៏ដូចជាអាជ្ញាធរនៅតាមច្រកទ្វារព្រំដែននីមួយៗត្រូវបន្តយកចិត្តទុកដាក់ទប់ស្កាត់អំពើឆ្លងដែនខុសច្បាប់របស់ប្រជាពលរដ្ឋ និងជនបរទេស និងខិតខំពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការនៅតាមច្រកទ្វារព្រំដែននីមួយៗជាមួយនឹងប្រទេសជិតខាងឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីបង្កើនការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។ ចំពោះបញ្ហាប្រឈម និងសំណូមពរផ្សេងៗរបស់អាជ្ញាធរខេត្ត និងមន្ទីរទាំងអស់ដែលបានលើកឡើង គណៈកម្មការទី៥ព្រឹទ្ធសភានឹងសិក្សាស្រាវជ្រាវ ហើយរាយការណ៍ជម្រាបជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងក្រសួងពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយរួមគ្នា។

ក្រៅពីជួបពិភាក្សាជាមួយនឹងអាជ្ញាធរខេត្តទាំងបី គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរស្រុកមណ្ឌលសីមា អាជ្ញាធរប្រចាំការនៅតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ខេត្តកោះកុង អាជ្ញាធរប្រចាំការកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងអាជ្ញាធរស្រុកកំពង់ត្រាច និងអាជ្ញាធរច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក ខេត្តកំពត ដើម្បីឈ្វេងយល់អំពីសកម្មភាពគ្រប់គ្រងច្រកទ្វារព្រំដែននីមួយៗ ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនបរទេសឆ្លងដែន ការអភិវឌ្ឍលើវិស័យនានា ព្រមទាំងចុះពិនិត្យមើលសកម្មភាពចេញ-ចូលរបស់ភ្ញៀវជាតិ-អន្តរជាតិ និងសកម្មភាពប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋនៅតាមច្រកទ្វារព្រំដែននីមួយៗ។ ក្រៅពីនេះ គណៈប្រតិភូក៏បានអញ្ជើញទស្សនកិច្ច និងពិនិត្យមើលការអនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវ ការរៀបចំតំបន់ឆ្នេរ និងដំណើរការអនុវត្តការងារនៅអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ ព្រមទាំងការរៀបចំបណ្ដាញប្រឡាយ និងដំណើរប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុផងដែរ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ ធុន គឹមជី)

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២សំណេះសំណាល អាជ្ញាធរក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តកំពង់ចាម




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២សំណេះសំណាលជាមួយអាជ្ញាធរខេត្តកំពង់ចាម*

ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុម បានអញ្ជើញចុះជួបសំណេះ-សំណាលជាមួយនឹងអាជ្ញាធរក្រុង ស្រុក និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ ស្រុកចំការលើ ស្រុកស្ទឹងត្រង់ ស្រុកកំពង់សៀម ស្រុកកោះសូទិន ស្រុកកងមាស និងក្រុងកំពង់ចាម ខេត្តកំពង់-ចាម សរុបចំនួន៤៦៥នាក់។

ពិធីសំណេះសំណាលរៀបចំឡើង ដើម្បីក្តាប់នូវស្ថានការណ៍ជាក់ស្តែង ប្រមូលព័ត៌មានលើការងារអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ចំពោះគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពទាំង៧ចំណុច ព្រមទាំងការត្រៀមខ្លួនដើម្បីឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។

ក្នុងឱកាសសំណេះសំណាលដាច់ដោយឡែកនៅក្រុង ស្រុកនីមួយៗ អាជ្ញាធរក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើសេចក្តីរាយការណ៍ជូនអង្គពិធីជ្រាបអំពី វឌ្ឍនភាពការងារ ការ



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

ផ្តល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការពង្រឹងសណ្តាប់ធ្នាប់ សុវត្ថិភាពសាធា-រណៈ ការចូលរួមដោះស្រាយវិវាទក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធតុលាការ បញ្ហាប្រឈម និងសំណូមពរនានា។

ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរក្រុង ស្រុក ក្រុមប្រឹក្សាឃុំ ដែលបានចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន។ ឯកឧត្តមបានបញ្ជាក់ថា អ្វីដែលត្រូវយកចិត្តទុកដាក់បំផុតចំពោះមុខនោះ គឺត្រូវអនុវត្តគោលនយោ-បាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពឱ្យបានល្អប្រសើរ ដើម្បីការពារផលប្រយោជន៍ជូនប្រជាពលរដ្ឋ ជាពិសេសត្រូវយកចិត្តទុកដាក់ក្នុងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅតាមឃុំរបស់ខ្លួនឱ្យបានម៉ត់ចត់។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាឃុំទាំង-អស់ត្រូវត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ ក្នុងការបោះ-ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ខាងមុខ។

ឯកឧត្តមប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានធ្វើការផ្តាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់សូមចូលរួម និងអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន សូមប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច ថែរក្សាសុខភាពកុំឱ្យឆ្លងជំងឺកូវីដ-១៩ ដោយអនុវត្តនូវវិធានការ ៣កុំ ៣ការពារ ឱ្យបានជាដាច់ខាត ព្រមទាំងទៅទទួលការចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន និងដូសជំរុញឱ្យបានគ្រប់ៗគ្នា ដើម្បីសុវត្ថិភាពសុខភាពយើងទាំងអស់គ្នា៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥សំណេះសំណាល ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងខេត្តតាកែវ




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥សំណេះសំណាលអាជ្ញាធរខេត្តតាកែវ*

កាលពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដឹកនាំដោយឯកឧត្តម **ខៀវ មុត** ប្រធានក្រុម និងជាអនុប្រធានគណៈម្មការទី១ បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក មេឃុំ ជំទប់ទី១ ជំទប់ទី២ ចៅសង្កាត់ ចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២ មកពីក្រុងដូនកែវ ស្រុកព្រៃកប្បាស ស្រុកអង្គរបូរី ស្រុកសំរោង ស្រុកបាទី ស្រុកកោះអណ្ដែត ស្រុកបូរីជលសារ ស្រុកទ្រាំង និងស្រុកគីរីវង់ ខេត្តតាកែវ សរុប២៤០នាក់។

ក្នុងឱកាសជួបសំណេះសំណាលដាច់ដោយឡែក ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានស្ដាប់សេចក្ដីរាយការណ៍របស់ថ្នាក់ដឹកនាំខេត្ត អំពីវិធានការ នៃការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការពង្រឹងសណ្ដាប់ធ្នាប់សុវត្ថិភាពសាធារណៈ ការចូលរួមដោះស្រាយវិវាទក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធតុលាការ ការផ្ដល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ព្រមទាំងការងារអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋានឱ្យបានកាន់តែប្រសើរឡើង។

ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ឯកឧត្តម **ខៀវ មុត** បានថ្លែងនូវការកោតសរសើរ និងអបអរសាទរ ចំពោះថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងអាជ្ញាធរពាក់ព័ន្ធក្នុងខេត្តតាកែវ ដែលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន សម្រេចបានលទ្ធផលសមិទ្ធផលយ៉ាងច្រើន និងមានការអភិវឌ្ឍសេដ្ឋកិច្ច សង្គម រីកចម្រើនជាលំដាប់។

ឯកឧត្តមបានបញ្ជាក់ថា ដើម្បីធានាបាននូវភាពជោគជ័យស្របតាមច្បាប់ គោលការណ៍ បែបបទនីតិវិធី និងក្រមសីលធម៌ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ សូមថ្នាក់ដឹកនាំក្រុង ស្រុក ឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវបន្តខិតខំធ្វើសកម្មភាពផ្អែកលើក្របខ័ណ្ឌនយោបាយ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌជំនាញបច្ចេកទេស ដើម្បីបម្រើជាតិនិងប្រជាជនឱ្យកាន់តែល្អប្រសើរឡើង ត្រូវខិតខំចូលរួមប្រឡងប្រណាំង ដើម្បីទទួលបាននូវកិត្តិយស និងស្នាដៃបន្ថែមទៀត ព្រមទាំងខិតខំអនុវត្តនូវគោលនយោបាយជាតិ និងរដ្ឋក្នុងការជួយប្រជាជនដែលមានទុក្ខលំបាកក្រីក្រ ជនពិការ ចាស់ជរា ស្ត្រី កុមារ និងអ្នករងគ្រោះពីធម្មជាតិផ្សេងៗ តាមរយៈការប្រើប្រាស់វិធានការសរុប កម្លាំងសរុប មធ្យោបាយសរុប។

ឯកឧត្តម **ខៀវ មុត** បានសង្កត់ធ្ងន់ថា កត្តាគន្លឹះជោគជ័យគ្រប់ភារកិច្ច គឺត្រូវខិតខំរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង ស្របតាមគោលការណ៍សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ហើយចេះរក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មីៗ ព្រមទាំងត្រូវយកចិត្តទុកដាក់ដល់មន្ត្រីមូលដ្ឋានបួនប្រភេទ គឺ៖ មេឃុំ ឬចៅសង្កាត់ ស្មៀន មេប៉ុស្តិ៍ និងមេភូមិ ដែលនៅកៀកនឹងប្រជាជនបំផុត ឱ្យខិតខំធ្វើអំពើល្អ ស្រឡាញ់ប្រជាជន បម្រើប្រជាជន ផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ រួសរាន់ដោះស្រាយរាល់បញ្ហាប្រឈម ការលំបាក ការខ្វះខាតរបស់មូលដ្ឋាន ឱ្យបានឆាប់រហ័ស ដោយតម្លាភាព និងមានយុត្តិធម៌ ស្របតាមលទ្ធភាពដែលខ្លួនមាន ហើយបញ្ហាណាដែលហួសពីសមត្ថកិច្ចរបស់ខ្លួនដោះស្រាយ សូមសុំយោបល់ពីថ្នាក់ដឹកនាំ ដើម្បីស្វែងរកយន្តការនៃការដោះស្រាយបន្ត ដើម្បីធ្វើឱ្យប្រជាជនមានការជឿទុកចិត្ត និងគោរពស្រឡាញ់អាជ្ញាធររដ្ឋគ្រប់លំដាប់ថ្នាក់។

ក្រៅពីចុះជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញថ្វាយបង្គំព្រះសង្ឃ ព្រមទាំងនាំយកទេយ្យវត្ថុប្រគេនដល់ព្រះសង្ឃនៅវត្តលឹមពូល វត្តព្រៃល្វា វត្តអំពិលបី វត្តកោះអណ្ដែត និងវត្តព្រៃមៀន៕

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦សំណេះសំណាលក្រុមប្រឹក្សាឃុំក្នុង ស្រុកស៊ីធរកណ្ដាល ស្រុកកំចាយមារ ស្រុកកញ្ជ្រៀច និងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦សំណេះសំណាលក្រុមប្រឹក្សាឃុំ ក្នុងស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង*

កាលពីថ្ងៃទី២៨ ដល់ថ្ងៃទី៣១ ខែមីនា និងថ្ងៃទី១១ ដល់ថ្ងៃទី១២ ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ ក្នុងស្រុកស៊ីធរកណ្ដាល ស្រុកកំចាយមារ ស្រុកកញ្ជ្រៀច និងស្រុកស្វាយអន្ទរ ស្រុកពោធិ៍រៀង និងស្រុកពារាំង ខេត្តព្រៃវែង។

ក្នុងឱកាសសំណេះសំណាលតាមស្រុកនីមួយៗ លោកអភិបាលស្រុក និងក្រុមប្រឹក្សាឃុំនីមួយៗ បានធ្វើសេចក្ដីរាយការណ៍អំពី វឌ្ឍនភាពការងារ ការផ្ដល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព បញ្ហាប្រឈម និងសំណូមពរនានា ព្រមទាំងការត្រៀមលក្ខណៈក្នុងការចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។

ក្នុងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ លោកជំទាវ **មាន សំអាន** បានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់អាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ ក្នុងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ អ្វីដែលអាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំទាំងអស់ត្រូវយកចិត្តទុកដាក់ គឺអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការផ្ដល់សេវាជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ដោយមិនប្រកាន់និន្នាការនយោបាយ។ ក្រៅពីនេះ ត្រូវត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់សម្រាប់ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះ។

លោកជំទាវ **មាន សំអាន** បានសង្កត់ធ្ងន់ថា ប្រទេសជាតិយើងទទួលបានសុខសន្តិភាពដូចសព្វថ្ងៃ ដោយសារតែមានការលះបង់គ្រប់បែបយ៉ាងរបស់ប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ ទើបធ្វើឱ្យប្រទេសយើងមានការអភិវឌ្ឍ និងរីកចម្រើនលើគ្រប់វិស័យ។ ដូច្នេះយើងទាំងអស់គ្នាត្រូវថែរក្សាសុខសន្តិភាពនេះឱ្យបានគង់វង្ស និងមិនអនុញ្ញាតឱ្យជនណាម្នាក់មកបំផ្លិចបំផ្លាញបានឡើយ។

លោកជំទាវបានអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ត្រូវថែរក្សាសុខភាពរបស់ខ្លួន និងជួយផ្សព្វផ្សាយជូនបងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ចចំពោះជំងឺកូវីដ-១៩ ជាពិសេសនាឱកាសពិធីបុណ្យចូលឆ្នាំខ្មែរឆ្នាំថ្មី ប្រពៃណីជាតិ។

សូមជម្រាបថា ពិធីសំណេះសំណាលនោះរៀបចំឡើង ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តការងារ ការគាំទ្រការអភិវឌ្ឍនានា បញ្ហាប្រឈម និងសំណូមពរនានា ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥៕

(អត្ថបទ និងរូបភាព៖ ធុន គីមជី)



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

# ឯកឧត្តម សុខ ឥសាន សំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ក្នុងស្រុកកំពង់ត្របែក ស្រុកព្រះស្ដេច និងស្រុកពាមរក៍ ខេត្តព្រៃវែង




*ឯកឧត្តម សុខ ឥសាន អញ្ជើញសំណេះសំណាលជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ នៅស្រុកពាមរក៍ ខេត្តព្រៃវែង*

នាថ្ងៃទី៣០ ទី៣១ ខែមីនា និងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ (ខេត្តព្រៃវែង និងខេត្តស្វាយរៀង) និងជាប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ ក្នុងស្រុកកំពង់ត្របែក ស្រុកព្រះស្ដេច និងស្រុកពាមរក៍ ខេត្តព្រៃវែង ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តការងារ ការគាំទ្រការអភិវឌ្ឍនានា បញ្ហាប្រឈម និងសំណូមពរនានា ការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ការងារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ។

បន្ទាប់ពីបានស្ដាប់នូវការរាយការណ៍របស់អភិបាលស្រុក និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ ធ្វើសេចក្ដីរាយការណ៍អំពីវឌ្ឍនភាពការងារ ការផ្ដល់សេវាសាធារណៈ ការអនុវត្តគោលនយោបាល ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការពង្រឹងសណ្ដាប់ធ្នាប់ សុវត្ថិភាពសាធារណៈ បញ្ហាប្រឈម និងសំណូមពរនានារួចមក ឯកឧត្តម **សុខ ឥសាន** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ ដែលបានបំពេញតួនាទីភារកិច្ច ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋបានល្អប្រសើរ និងបានចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

ឯកឧត្តម **សុខ ឥសាន** បានក្រើនរំលឹកដល់អាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំទាំងអស់ ត្រូវបន្ដយកចិត្តទុកដាក់ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ឱ្យបានល្អប្រសើរ ដើម្បីការពារផលប្រយោជន៍ជូនប្រជាពលរដ្ឋ ជាពិសេសត្រូវបន្ដយកចិត្តទុកដាក់ផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរថែមទៀត។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ខាងមុខ៕

(អត្ថបទ និងរូបភាព៖ ធុន គីមជី)





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

# ក្រុមសមាជិកាព្រឹទ្ធសភាសំណេះសំណាលសមាជិកា ក្រុមប្រឹក្សាឃុំ សង្កាត់មកពីខេត្តកំពត និងខេត្តកែប




*ក្រុមសមាជិកាព្រឹទ្ធសភាសំណេះសំណាលសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់មកពីខេត្តកំពត និងខេត្តកែប*

នាព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ ក្រុមសមាជិកាព្រឹទ្ធសភា បានរៀបចំពិធីជួបសំណេះសំណាលជាមួយនឹងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ មកពីខេត្តកំពត និងខេត្តកែប ក្រោមអធិបតីភាពលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ដោយមានការចូលរួមពីឯកឧត្តម **ម៉ៅ ធនិន** អភិបាល នៃគណៈអភិបាលខេត្តកំពត ប្រធានក្រុមប្រឹក្សាខេត្ត សមាជិកាក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្តជាស្ត្រី នៃខេត្តទាំងពីរ តំណាងរាស្ត្រខេត្តកំពត មន្ទីរជំនាញពាក់ព័ន្ធនានាជុំវិញខេត្ត សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារសរុបចំនួន ២១០នាក់ នៅសាលប្រជុំសាលាខេត្តកំពត។

សូមជម្រាបថា ពិធីសំណេះសំណាលរៀបចំឡើងក្នុងគោលបំណង៖ ទី១-ដើម្បីលើកទឹកចិត្ត និងបង្កើនទំនាក់ទំនងភាពជិតស្និទ្ធរវាងក្រុមសមាជិកាព្រឹទ្ធសភាជាមួយនឹងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់។ ទី២-រួមគ្នាក្នុងការចូលរួមពង្រឹងពង្រីកការអភិវឌ្ឍនៅមូលដ្ឋានឱ្យកាន់តែប្រសើរឡើង ឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២។ ទី៣-ការផ្តល់ឱកាសដល់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងបេក្ខនារីឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ បញ្ចេញមតិយោបល់ សំណួរ បញ្ហាប្រឈម និងសំណូមពរ ព្រមទាំងចែករំលែកបទពិសោធន៍ក្នុងការបំពេញការងារ។ ទី៤-ការពង្រឹង និងលើកកម្ពស់សមត្ថភាព ភាពក្លាហាន ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តរបស់បេក្ខនារីឱ្យកាន់តែប្រសើរឡើង និងចូលរួមជ្រើសរើសអ្នកដឹកនាំក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានសមត្ថភាពពិតប្រាកដ ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរ និងទី៥-ការលើកកម្ពស់សមភាពយេនឌ័រ និងសុខភាពសាធារណៈ ការរស់នៅ និងការធ្វើការងារតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។

ក្នុងនាមក្រុមសមាជិកាព្រឹទ្ធសភា លោកជំទាវ **មាន សំអាន**




*ក្រុមសមាជិកាព្រឹទ្ធសភាសំណេះសំណាលសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់មកពីខេត្តកំពត និងខេត្តកែប*



ទិដ្ឋភាពក្នុងពិធីសំណេះសំណាល

បានធ្វើការកត់សម្គាល់ថា ស្ត្រីកម្ពុជាតែងទទួលបានកាលានុវត្តភាព ដោយមានការចូលរួមគ្រប់កិច្ចការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ ទាំងផ្នែកវិស័យសាធារណៈ សន្តិសុខ នយោបាយ ការទូតឯកជន អង្គការជាតិ-អន្តរជាតិ និងត្រូវបានលើកទឹកចិត្តឱ្យចាប់យកតួនាទីសំខាន់ៗដោយស្មើភាព និងគ្មានការរើសអើង។ ដោយបច្ចុប្បន្នស្ត្រីក្នុងភាពជាអ្នកដឹកនាំកាន់តែមានចំនួនកើនឡើងជាលំដាប់ ស្របទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលបានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ ហើយទោះបីចំនួនស្ត្រីក្នុងជួរថ្នាក់ដឹកនាំកើនឡើងក៏ដោយក៏នៅពុំទាន់សមស្របទៅតាមតម្រូវការចាំបាច់។

លោកជំទាវ **មាន សំអាន** បានលើកទឹកចិត្ត និងក្រើនរំលឹកដល់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ សូមយកចិត្តទុកដាក់បន្តអនុវត្តការងារតាមតួនាទីភារកិច្ចរបស់ខ្លួនក្នុងការបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អ និងយកចិត្តទុកដាក់បន្ថែមលើការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់។

ជាមួយគ្នានោះ លោកជំទាវ បានក្រើនរំលឹកដល់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបន្តប្រុងប្រយ័ត្នខ្ពស់ មិនត្រូវភ្លេចការពារខ្លួនពីជំងឺកូវីដ-១៩ និងសូមអំពាវនាវឱ្យបងប្អូនមេត្តាបន្តអនុវត្តនូវវិធានការសុខាភិបាលឱ្យបានខ្ជាប់ខ្ជួន និងហ្មត់ចត់ ដើម្បីទទួលបានសុខភាពល្អប្រសើរ បន្តប្រតិបត្តិការងារ និងប្រកបជីវភាពប្រចាំថ្ងៃទៅតាមគន្លងថ្មីជាមួយនឹងជំងឺរាតត្បាតកូវីដ-១៩ ដែលមិនទាន់រលត់សាបសូន្យនៅឡើយ។

ពិធីសំណេះសំណាលបានប្រព្រឹត្តទៅរយៈពេលមួយព្រឹក ដោយមានកម្មវិធីដូចជា៖ ទស្សនាខ្សែវីដេអូ ស្តីពីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងវឌ្ឍនភាពការងាររបស់ក្រុមសមាជិកាព្រឹទ្ធសភា ឆ្នាំ២០២១។ មតិស្វាគមន៍របស់ឯកឧត្តម **ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត និងការចូលរួមមតិយោបល់ សំណួរ បញ្ហាប្រឈម និងសំណូមពររបស់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងមតិយោបល់ និងការចូលរួមផ្តល់អនុសាសន៍ល្អៗពីក្រុមសមាជិកាព្រឹទ្ធសភា ពាក់ព័ន្ធនឹងវឌ្ឍនភាព និងការឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២។ ដោយឡែក ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ឆី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាមួយនឹង ឯកឧត្តម **ម៉ៅ ធនិន** អភិបាល នៃគណៈអភិបាលខេត្តកំពត ជួបសំណេះសំណាល និងចែកអំណោយជូនដល់បងប្អូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត បងប្អូនដែលមានមុខរបរមិនទៀងទាត់ និងបងប្អូនគ្រួសារម៉ូតូឌុប សរុបចំនួន៣៥០នាក់ ដោយក្នុងម្នាក់ៗទទួលបានអង្ករ១០គីឡូក្រាម ព្រមទាំងសម្ភារមួយចំនួន៕

(អត្ថបទ៖ អ៊ុក ប៉ូលីន និងរូបភាព៖ ធុន គីមជី)



ក្រុមសមាជិកាព្រឹទ្ធសភាថតរូបអនុស្សាវរីយជាមួយ
សមាជិកាក្រុមប្រឹក្សាឃុំមកពីខេត្តកំពត និងខេត្តកែប

# ឯកឧត្តម សុខ ឥសាន ផ្ដល់អនុសាសន៍ចំនួន២ចំណុច ដើម្បីប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងសេរីភាពសារព័ត៌មាន





*ឯកឧត្តម សុខ ឥសាន អញ្ជើញជាអធិបតីភាពក្នុងពិធីបិទសិក្ខាសាលាស្ដីពី ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងសេរីភាពសារព័ត៌មាន*

ឯកឧត្តម**សុខ ឥសាន**ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងជាអនុប្រធានក្រុមសភាជាតិកម្ពុជាAPF បានផ្ដល់អនុសាសន៍ចំនួន២ចំណុច ដើម្បីជាដំណោះស្រាយយូរអង្វែង និងនិរន្តរភាពក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងសេរីភាពសារព័ត៌មាន គឺត្រូវធ្វើយុទ្ធនាការជាអាទិ៍៖**១**-ការអប់រំចាប់ពីយុវជនវ័យក្មេងឡើងទៅឱ្យមានចំណេះដឹងផ្នែកសារព័ត៌មាន និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយការទទួលខុសត្រូវ។ **២**-ការអប់រំប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន តាមរយៈការបញ្ជូនជំនាញប្រព័ន្ធផ្សព្វផ្សាយ និងលេខកូដឌីជីថល ភាសា និងការអនុវត្តគឺជាវិធីល្អបំផុតដើម្បីបែងចែករវាងព័ត៌មានប្រកបដោយគុណភាព និងព័ត៌មានក្លែងក្លាយ។

ឯកឧត្តម **សុខ ឥសាន** បានផ្ដល់អនុសាសន៍យ៉ាងដូច្នេះ ក្នុងឱកាសដែលឯកឧត្តមអញ្ជើញជាអធិបតីភាពក្នុងពិធីបិទសិក្ខាសាលាស្ដីពី ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងសេរីភាពសារព័ត៌មាន៖ បញ្ហាប្រឈម និងដំណោះស្រាយ? នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា និងស្ថាប័នសារព័ត៌មានមួយចំនួននៅកម្ពុជាសរុបជាង១០០នាក់។

ឯកឧត្តម **សុខ ឥសាន** បានបញ្ជាក់យ៉ាងច្បាស់ថា នៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ សេរីភាពសារព័ត៌មាន គឺជាធាតុផ្សំដ៏ចម្បងក្នុងការអភិវឌ្ឍសង្គមរបស់ខ្លួនលើគ្រប់វិស័យទាំងនយោបាយ សេដ្ឋកិច្ច និងសង្គម។ ហេតុដូច្នេះ ចាប់តាំងពីប្រទេសកម្ពុជាបានទទួលសន្តិភាព និងស្ថិរភាពនយោបាយមកមានការរីកចម្រើនជាច្រើននូវ សារព័ត៌មាន ស្ថានីយវិទ្យុ ទូរទស្សន៍ ព្រឹត្តប័ត្រ ទស្សនាវដ្ដី ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឌីជីថល បាននឹងកំពុងធ្វើសកម្មភាពយ៉ាងទូលំទូលាយ។ ប៉ុន្តែសិទ្ធិ និងសេរីភាពដែលជាមូលដ្ឋានគ្រឹះ នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ជួនកាលត្រូវបានគេបំភាន់ ដូចនៅប្រទេសកម្ពុជាក៏ដូចជាបណ្ដាប្រទេសនានានៅជុំវិញពិភពលោក។ ការគ្មានសណ្ដាប់ធ្នាប់ គឺជាផ្នែកមួយដែលបណ្ដាលឱ្យស្គាល់នូវព័ត៌មានក្លែងក្លាយ ការផ្សព្វផ្សាយព័ត៌មានមិនពិត ឬការមិនគោរពក្រមសីលធម៌ និងព័ត៌មានលាបពណ៌ភ្ជាប់នឹងនិន្នាការនយោបាយមនោគមវិជ្ជាបម្រើនយោបាយ និងបម្រើមហិច្ឆតាក្រុមឬបុគ្គលដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គល សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ហើយក៏អាចនាំឱ្យមានអស្ថិរភាពក្នុងសង្គមទៀតផង។

ឯកឧត្តម **សុខ ឥសាន** បានបញ្ជាក់ថា អំពីព័ត៌មានក្លែងបន្លំ និងព័ត៌មានមិនពិត មិនមែនជាបាតុភូតថ្មីនោះទេ ប៉ុន្តែជាបច្ចេកទេសក្នុងការចរាចរណ៍ព័ត៌មានមិនពិតនៅលើបណ្ដាញក្នុងទម្រង់ឌីជីថល ដែលត្រូវបានបែងចែកជាបីប្រភេទ ដែលធ្វើឱ្យការគ្រប់គ្រងមានការលំបាកយ៉ាងខ្លាំង។ ហេតុដូច្នេះ ជាការចាំបាច់ណាស់ក្នុងការស្វែងរកដំណោះស្រាយដ៏សមស្របដើម្បីជៀសវាងបាតុភាពអវិជ្ជមានទាំងឡាយ។ ឯកឧត្តមបានស្នើដល់ប្រព័ន្ធផ្សព្វផ្សាយ និងបុគ្គលដែលធ្វើការក្នុងវិស័យសារព័ត៌មានត្រូវគោរពក្រមវិជ្ជាជីវៈសារព័ត៌មាន និងផ្សព្វផ្សាយតែព័ត៌មានដែលអាចទុកចិត្តបាន និងដោយផ្ទៀងផ្ទាត់ ហើយមិនទាញយកអត្ថប្រយោជន៍ពីតួនាទីរបស់ខ្លួនទៅបម្រើផលប្រយោជន៍បុគ្គល ឬក្រុមណាមួយឡើយ។

ឯកឧត្តម **សុខ ឥសាន** បានថ្លែងនូវការអបអរសាទរ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះវាគ្មិន ដែលបានរួមចំណែកយ៉ាងសំខាន់នៅក្នុងអង្គសិក្ខាសាលា។ ឯកឧត្តមមានសេចក្ដីសោមនស្សរីករាយនូវលទ្ធផលជាផ្លែផ្កាដែលកើតចេញពីការជជែកពិភាក្សានៅក្នុងអង្គសិក្ខាសាលា ដែលនឹងរួមវិភាគទានមួយចំនួនក្នុងការកសាងសេចក្ដីព្រាងច្បាប់ស្ដីពី សិទ្ធិទទួលបានព័ត៌មានដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងដំណើរការ។

គួររំលឹកថា សិក្ខាសាលាខាងលើនេះបានដំណើរការប្រព្រឹត្តទៅរយៈពេលមួយថ្ងៃកន្លះ ពីថ្ងៃទី៦ និងព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ ក្រោមកិច្ចសហការរៀបចំដោយព្រឹទ្ធសភា រដ្ឋសភា និងកម្មវិធីនុយមេរិក នៃសភាប្រើភាសាបារាំង (APF)៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្តម **យង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញដឹកនាំៈ



-ប្រជុំជាមួយនឹងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រីការិយាល័យភូមិភាគទី៤ និងទី៥ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។



-ប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើរបាយការណ៍លទ្ធផលការងារចុះជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក ឃុំ នៃស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងពិនិត្យគម្រោងថវិកាសម្រាប់គាំទ្រកិច្ចប្រជុំនៅតាមមូលដ្ឋាន ព្រមទាំងការត្រៀមគម្រោងចុះបេសកកម្មរបស់គណៈកម្មការនៅពេលខាងមុខ និងបញ្ហាផ្សេងៗមួយចំនួន នាថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។



-ប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដើម្បីត្រៀមរៀបចំពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំស្តីពី ការងារបោះឆ្នោត នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង និងស្រុកកូនមុំ ខេត្តរតនគិរី នាព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

❈នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ជា ជេដ្ឋ**



ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំស្តីពីការត្រៀមបំពេញបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញៈ



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៣ព្រឹទ្ធសភា នារសៀលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើៈ

១-គម្រោងកម្មវិធីបេសកកម្មរបស់គណៈកម្មការទៅខេត្តកំពង់ស្ពឺ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ ខាងមុខ។

២-បញ្ហាផ្សេងៗ។



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៣ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំពិសេសព្រឹទ្ធសភា។

-ដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការនានាព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ



សិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំពិសេសព្រឹទ្ធសភា។



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៣ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សា អំពីកម្មវិធីបំពេញបេសកកម្មរបស់គណៈកម្មការទៅខេត្តកំពង់ស្ពឺ នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា។

❋លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំ៖

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-របាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងាររបស់គណៈកម្មការទី៥ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២។
២-បិទបញ្ជីថវិកាចំណូល-ចំណាយរបស់គណៈកម្មការទី៥ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២។
៣-បញ្ហាផ្សេងៗ។



-ប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បីត្រៀមចុះឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍលើវិស័យនានារបស់ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត និងចុះពិនិត្យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងនៅតាមច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។



-ប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បីពិនិត្យរបាយការណ៍បឋមក្រោយទៅសិក្សាឈ្វេងយល់អំពី ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍលើវិស័យនានារបស់ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត និងទៅពិនិត្យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងនៅតាមច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។



-ប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-របាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងាររបស់គណៈកម្មការប្រចាំខែមេសា ឆ្នាំ២០២២។
២-របាយការណ៍ចុះបេសកកម្មនៅខេត្តកោះកុង ខេត្តព្រះ-សីហនុ និងខេត្តកំពត កាលពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។
៣-ទស្សនាវីដេអូសកម្មភាពចុះបំពេញបេសកកម្មនៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ និងចុះបេសកកម្មនៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត កាលពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។
៤-សេចក្ដីរាយការណ៍អំពីសភាពការណ៍អន្តរជាតិថ្មីៗ អំពីសង្គ្រាមប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន។
៥-បញ្ហាផ្សេងៗ។

❋នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិនិត្យ ពិភាក្សា និង



ត្រៀមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា។



❋នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីពិនិត្យផែនការសកម្មភាពការងារនៅចន្លោះសម័យប្រជុំ ជំរុញសកម្មភាពការងារនៅតាមមូលដ្ឋានភូមិភាគ ជាពិសេសការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យប្រុងប្រយ័ត្នការពារកុំឱ្យមានការឆ្លងរាលដាលជំងឺកូវីដ-១៩។



❋នារសៀលថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកាព្រឹទ្ធសភា តាមរយៈប្រព័ន្ធវីដេអូ (Zoom) ដើម្បីពិនិត្យពិភាក្សាអំពីការត្រៀមរៀបចំពិធីសំណេះ-សំណាលរវាងក្រុមសមាជិកាព្រឹទ្ធសភា ជាមួយនឹងសមាជិកាក្រុម-ប្រឹក្សាឃុំ សង្កាត់ មកពីខេត្តកំពត និងខេត្តកែប និងបញ្ហាផ្សេងៗ។

❋នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៩) ដើម្បីពិនិត្យពិភាក្សា



និងត្រៀមឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិនិងភូតគាមអនាម័យ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❋នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុនណាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យលើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារ របាយ-ការណ៍ថវិកាប្រចាំខែមេសា ឆ្នាំ២០២២ និងពិនិត្យសម្រេចលើកម្មវិធីចុះបំពេញបេសកកម្មនៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❋នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយនឹងមន្ត្រីការិយាល័យភូមិភាគទី២ ដើម្បីពិនិត្យលើរបាយការណ៍របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិ-ភាគទី២ ដែលបានសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំនៅខេត្តត្បូងឃ្មុំ និងផែនការរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដែលនឹងគ្រោងបន្តចុះជួបជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តកំពង់ចាម នាពេលខាងមុខ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❈នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **យង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរជាមួយនឹងបងប្អូនប្រជាពលរដ្ឋ អាជ្ញាធរសង្កាត់រកាកណ្តាល ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមយុវជនរៀបចំសម្តែងសិល្បៈ នៅសង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ ។



❈ឯកឧត្តម **យង់ សែម** ប្រធាន ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានបេតុង ឆ្លងស្ទឹងសែន ខេត្តកំពង់ធំ និងពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅវត្តកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។



❈នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ខា ខេឌ្ឍ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំគណៈកម្មការច្បាប់ និងនីតិវិធីបោះឆ្នោត ស្តីពីផែនការឆ្ពោះទៅការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារវិស្វករសំណង់ចុះពិនិត្យមើលប្រាសាទព្រះវិហារនិមិត្តរូប ដែលទើបសាងសង់ ហើយរួចជាស្ថាពរ និងចុះពិនិត្យមើលក្រុមការងារសំណង់សាងសង់ចេតិយរួមនៅលើកំពូលភ្នំកម្ពស់១៣០ម៉ែត្រ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាលសួរសុខទុក្ខកម្មករ ពិនិត្យទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា ព្រមទាំងចុះពិនិត្យមើលការងារជីកប្រឡាយរំដោះជំនន់ទឹកភ្លៀង នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២។

-ជួបលោកបណ្ឌិត **និន ចិន្តា** ឯកទេសសង្គ្រោះបន្ទាន់ និងជំងឺធ្ងន់ ដើម្បីចុះពិនិត្យមើលមន្ទីរពេទ្យព្យាបាល ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋកំពុងប្រមូលផលផ្លែស្វាយកែវរមៀត និងចុះពិនិត្យមើលការងារសាងសង់ទំនប់រំដោះជំនន់ទឹកភ្លៀង នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងណែនាំកម្មករកំពុងប្រមូលផលផ្លែស្វាយ និងអំពីរបៀបតែងមែកស្វាយ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ  នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាលសួរសុខទុក្ខកម្មករប្រមូលផលផ្លែស្វាយប៉ោមអូស្ត្រាលី និងពិនិត្យមើលទំនប់ទឹកដែលអាចស្តុកទឹកបាន៣០០.០០០ម៉ែត្រគូប សម្រាប់បំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាលសួរសុខទុក្ខកម្មករ និងដឹកនាំក្រុមការងារកសិកម្មរួមជាមួយនឹងវិស្វករសំណង់ ចុះពិនិត្យនិងដាក់ផែនការការងារអភិវឌ្ឍន៍បន្តទៀត ព្រមទាំងចូលរួមពិធីអបអរសាទរពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរជាមួយនឹងកម្មករ និងប្រជាពលរដ្ឋ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។

-ជួបលោក **សឿង ម៉ូរ៉ារិទ្ធ** ប្រធាននាយកគ្រប់គ្រងធនាគារពាណិជ្ជកម្ម ឈីហ្វ (ខេមបូឌា) នាំយករថយន្តសង្គ្រោះបន្ទាន់១គ្រឿង មកជួយបម្រើការងារដឹកជញ្ជូនអ្នកជំងឺសម្រាកព្យាបាល នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២។

-ចូលរួមពីធីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ជាមួយនឹងប្រជាពលរដ្ឋ ព្រមទាំងនាំយកអំណោយ និងថវិកាមួយចំនួនទៅប្រគេនព្រះសង្ឃ នៅវត្តឫទ្ធីរតនារាម ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ ដែលអញ្ជើញមកសម្រាកកម្សាន្តក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំ-សែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៦ ខែមេសា ឆ្នាំ ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធ សំណង់ទំនប់ទឹក និងផ្លូវនានា នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងកុមារកុមារី ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅភ្នំសែនដី ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ស្ទោរ សង្កាត់ឪឡោក និងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ នៅសាលាសង្កាត់ស្ទោរ ខណ្ឌកំបូល រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈ និងការចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។



-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈ និងការចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២។



❈នាព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំ និងមន្ត្រី នៃមន្ទីរសុខាភិបាល (ជាស្ត្រី) អ្នកគ្រូពេទ្យ ថ្នាក់ដឹកនាំ និងមន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡា (ជាស្ត្រី) នាយិកាសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងសិស្សនារីក្រីក្រថ្នាក់ទី១២សរុបចំនួន១៥០នាក់ នៅខេត្តព្រៃវែង។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាគណៈអធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារ និងសមិទ្ធផលនានារបស់រដ្ឋបាលខេត្តកណ្តាល និងចូលរួមពិធីសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតី-ភាព ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧប-នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅភូមិទួល-



ក្រសាំង សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២។

-នាំយកទេយ្យទាន និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃគង់នៅវត្តអង្គចំប៉ី វត្តអង្គរំចេក និងវត្តប្រាងសុវណ្ណ នៅឃុំទូកមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២។



❈នាព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា លោកជំទាវ **ភេខ សៅរ៍ធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីសម្ពោធឆ្លង "មហាកុដិ" ក្នុងវត្តព្រៃតុម្ព នៅភូមិព្រៃតុម្ព ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក។

❈ឯកឧត្ត **ឈួន ឡេខ** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងនាំយកថវិការបស់ក្រុមភូមិភាគឧបត្ថម្ភឃុំ ព្រមទាំងសំណេះសំណាលគ្រួសារក្រីក្រចំនួន៥គ្រួសារ និងបានជួយឧបត្ថម្ភជាសម្ភារ និងថវិកាមួយចំនួន នៅសាលាស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២៤ និងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាលថ្នាក់ដឹកនាំភូមិទូទាំងឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង ចំនួន៧២នាក់ ដើម្បីផ្សព្វផ្សាយផែនការ និងពិភាក្សាការងារសំខាន់ៗឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលនានាក្នុងវត្តពោធិតុម្ព ហៅវត្តព្រៃមាន់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅភូមិព្រៃមាន់ ឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។

❈នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ឈិត**



**គឹមឃាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តសុវណ្ណមូលី (គគីរប្រាប) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចធម្មវិសុទ្ធវង្សា នៅភូមិគគីរ-ប្រាប ឃុំល្វៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❈នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាល និងពិភាក្សាការងារនៅថ្នាក់ខេត្ត ក្រុងខេមរភូមិន្ទ និងសង្កាត់ស្មាច់មានជ័យ សង្កាត់ដងទង់ និងសង្កាត់ស្ទឹងវែង នៅក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ប្រជុំជាមួយនឹងលោកប្រធានភូមិទាំង១៣ និងក្រុមប្រឹក្សា



សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្ដាប់របាយការណ៍ ស្ដីពីលទ្ធផលការងារ និងទិសដៅការងារសម្រាប់អនុវត្តបន្ត ការងាររៀបចំកម្លាំងការពារសន្តិសុខសណ្ដាប់ធ្នាប់ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។



-ជួបសំណេះសំណាលមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងឧបត្ថម្ភលើកទឹកចិត្តលើការខិតខំបំពេញការងារសន្តិសុខ និងអនាម័យ នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២។



-ប្រជុំជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដោយសម្ដែងនូវការពេញចិត្ត និងកោតសរសើរចំពោះការធានាបាននូវសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២។

-ប្រជុំជាមួយប្រធានភូមិទាំង១៣ និងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្ដាប់របាយ-



ការណ៍ស្ដីពី លទ្ធផលការងារខែមេសា និងទិសដៅជាអាទិភាពសំខាន់ៗ ខែឧសភា ឆ្នាំ២០២២ បន្តពង្រឹងការងារសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ ការងារផ្ដល់សេវាជូនប្រជាពលរដ្ឋពិសេសការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២។

❈នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខជាមួយនឹងគ្រួសារប្រជាពលរដ្ឋក្រីក្រ នៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភា និងឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលមន្ត្រីចូលនិវត្តន៍ លោកគ្រូ អ្នកគ្រូបឋម និងមត្តេយ្យសហគមន៍ ដែលមានវត្តមានចូលរួម៦៥នាក់ នៅវិទ្យាល័យព្រះពន្លា ព្រមទាំងជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងឧបត្ថម្ភថវិកា សម្ភារជូនចាស់ជរាចំនួន៦គ្រួសារ ព្រមទាំងសួរសុខទុក្ខក្រុមគ្រួសារនៃសព នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៧ ខែមីនាឆ្នាំ២០២២។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំចំនួន១២៤នាក់នៅឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។



❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំមកពីស្រុកកំពង់រោទិ៍ និងស្រុកស្វាយទាប ចំនួន១២២នាក់ នៅខេត្តស្វាយរៀង ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ មកពីស្រុកចន្ទ្រា និងក្រុងបាវិត ចំនួន៦១នាក់ នៅខេត្តស្វាយរៀង នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋចាស់ជរា ចំនួន១២គ្រួសារ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៣ និងថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពលោកស្រី **អ៊ុក យឿន** មន្ត្រីចូលនិវត្តន៍ នៅភូមិពាណិជ្ជកម្ម សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពលោក **ឈួន ម៉ុនថន** សមាជិកក្រុមប្រឹក្សាឃុំវល្លិសរ នៅភូមិក្រាំងពង្រ ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុកសំរោងទង ដើម្បីការត្រួតពិនិត្យការងារឆ្ពោះទៅកាន់ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ និងលើកទិសដៅការងារបន្ត នៅសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២។

❈នាថ្ងៃទី៦ និងថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋក្នុងស្រុកសំឡូត ខេត្តបាត់ដំបង។

❈នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **គិន ណៃឆ** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញរៀបចំពិធីបង្សុកូលជូនជីដូន ជីតា ញាតិ ដែលបានចែកឋានទៅកាន់លោកខាងមុខ និងធ្វើពិធីបួងសួងសុំសេចក្តីសុខសប្បាយ នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦ ព្រមទាំងចែកអំណោយដល់ប្រជាពលរដ្ឋក្រីក្រ ចំនួន៣០គ្រួសារ ។

❈ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ជូននិស្សិតជ័យលាភី ចំនួន៥៣៨រូប នៅសាកលវិទ្យាល័យជាតិមានជ័យ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសម្ពោធឆ្លងមហាកុដិថ្មី និងសមិទ្ធផលនានាក្នុងវត្តទក្ខិណាគង្គារាម ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៩ ខែមេសា ឆ្នាំ

២០២២។

-ក្នុងពិធីសំណេះសំណាល និងសួរសុខទុក្ខកងកម្លាំង ដែលកំពុងឈរជើងក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះជួបសំណេះសំណាល សួរសុខទុក្ខ និងចែកកញ្ចប់អាហារសម្រាប់ស្រាយបួសក្នុងខែរ៉ម៉ាឌន ជូនប្រជាពលរដ្ឋជាសាសនិកខ្មែរឥស្លាមចំនួន១.២៤០គ្រួសារ នៅស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៨ ទី២៩ ទី៣១ ខែមីនា ថ្ងៃទី១៨ និងទី១៩ ខែមេសា ឆ្នាំ២០២២។



-ចុះជួបសំណេះសំណាល សួរសុខទុក្ខ និងចែកកញ្ចប់អាហារសម្រាប់ស្រាយបួសក្នុងខែរ៉ម៉ាឌន ជូនបងប្អូនខ្មែរសាសនិកឥស្លាមចំនួន១០០គ្រួសារ នៅភូមិប៉ារ៉ែនក្រោម ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋជួបការលំបាកចំនួន៦គ្រួសារ នៅឃុំស្វាយតាយាន ឃុំញរ និងឃុំរាជមន្ទីរ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ និងសហគមន៍ភូមិខ្វាវខាងលិច សរុបចំនួន៧០នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសាលាបឋមសិក្សាខ្វាវលិច ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងកម្មវិធីសម្ពោធអគាររដ្ឋបាលឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងកម្មវិធីបើកសង្ក្រាន្ត អបអរសាទរពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ និងឧបត្ថម្ភថវិកាមួយចំនួន នៅវត្តស្វាយចេក ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២។

-ចូលរួមពិធីបិទសង្ក្រាន្តបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិខ្មែរ និងចែកអំណោយជូនបងប្អូនប្រជាពលរដ្ឋ ចាស់ជរា ចំនួន៤៤០នាក់ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅប្រាសាទបន្ទាយឆ្មា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២។

-ចូលរួមរំលែកមរណទុក្ខដល់គ្រួសារសពលោក **ចន់ កុសល់** មន្ត្រីចូលនិវត្តន៍នៃមន្ទីរព័ត៌មាន នៅភូមិអញ្ចាញ ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២។

-នាំយកថវិកា និងស័ង្កសី ជូនលោកអភិបាលស្រុក ដើម្បីជួយដល់ប្រជាពលរដ្ឋចំនួន៤ឃុំដែលរងគ្រោះដោយខ្យល់កន្ត្រាក់

ខូចខាតផ្ទះ ចំនួន៨២ខ្នង នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលលោកគ្រូ អ្នកគ្រូគ្រប់សាលាទូទាំងស្រុកអូររាំងឪ មន្ត្រីការិយាល័យអប់រំស្រុក នៅសាលាស្រុកអូររាំងឪ ព្រមទាំងជួបសំណេះសំណាលប្រធានភូមិជំនួយការភូមិ និងប្រធានក្រុមទូទាំងឃុំមៀន ដើម្បីផ្សព្វផ្សាយការងារត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅសាលាបឋមសិក្សាបន្ទាយមៀន ស្ថិតក្នុងស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៩ ខែមេសាឆ្នាំ២០២២។



-ជាកិត្តិយសក្នុងពិធីសូត្រមន្តអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។

❋នាថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ថុង ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ នៅស្រុកមណ្ឌលសីមា និងក្រុមខេមរភូមិន្ទ ក្នុងខេត្តកោះកុង។

❋ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះជួបសំណេះសំណាលក្រុមប្រឹក្សាឃុំត្រពាំងគរ ដើម្បីឈ្វេងយល់សកម្មភាពក្រុមប្រឹក្សាឃុំ និងចូលរួមដោះស្រាយបញ្ហាប្រឈមនានាកើតឡើងក្នុងឃុំ និងការងារជួសជុលផ្លូវក្នុងភូមិចំនួន២ខ្សែ សាងសង់ផ្ទះមួយខ្នងអំពីដែកជូនស្ត្រីទីទាល់ក្រ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២។



-ដឹកនាំក្រុមគ្រូពេទ្យរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅភូមិព្រៃកតានង់ក្នុងឃុំព្រៃកតានង់ ស្រុកកោះសូទិន ខេត្តកំពង់ចាម នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **ញ៉ូវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកចង្ហាន់ ទេយ្យវត្ថុ គ្រឿងឧបភោគបរិភោគ ព្រមទាំងបច្ច័យប្រគេនព្រះសង្ឃក្នុងវត្តពោធិ៍សុវណ្ណរង្សី វត្តនទីសេដ្ឋាហៅវត្តបន្ទាយយួន វត្តកែវវិជ័យ វត្តពោធិវង្ស វត្តព្រៃខ្លុង វត្តនទីមង្គល ហៅវត្តកំពង់ក្រសាំង ដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់បុព្វការីជន និងអ្នកស្នេហាជាតិដែលបានពលីជីវិតទៅកាន់លោកខាងមុខ នៅខេត្តពោធិ៍សាត់ នាថ្ងៃទី២ ទី៣ ទី១៤ ទី១៥ ទី១៦ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខលោកគ្រូ អ្នកគ្រូវិទ្យាល័យកោះសូទិន និងមន្ទីរពេទ្យបង្អែក ព្រមទាំងនាំអំណោយរួមមាន៖ Computerចំនួន២០គ្រឿង និងម៉ាស៊ីនអុកស៊ីហ្សែនចំនួន៣គ្រឿង និងថវិកាមួយចំនួន ដែលជាអំណោយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ប្រគល់ជូនវិទ្យាល័យឃុំកោះសូទិន និងមន្ទីរពេទ្យបង្អែក នៅស្រុកកោះសូទិន ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២។

-សហការជាមួយនឹងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះព្យាបាលជំងឺជូនប្រជាពលរដ្ឋចំនួន២៣៧នាក់ នៅឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២។

-ចុះពិនិត្យមើលសកម្មភាពការព្យាបាលជំងឺ និងចាប់សរសៃជូនប្រជាពលរដ្ឋចំនួន១០០នាក់ ព្រមទាំងចែកថ្នាំលាបរឹត កៅ-

អៀក ខ្សែក្រវាត់រឹតចង្កេះ និងក្រមា នៅឃុំព្រែកតានង់ ស្រុកកោះសូទិន ខេត្តកំពង់ចាម នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រចំនួន១៦០នាក់ នៅឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលប្រជាពលរដ្ឋ នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ ព្រមទាំងជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋជនជាតិឥស្លាម ព្រមទាំងចុះចែកអំណោយដល់ពួកគាត់ចំនួន១០០គ្រួសារជាកញ្ចប់អាហារ នៅភូមិម៉ាក់ប្រាង ឃុំកំពង់គ្រែង នៅស្រុកកំពង់ត្រាច ខេត្តកំពត នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចែកកញ្ចប់អាហារសម្រាប់បួសចំនួន១៥០គ្រួសារ នៅភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នាព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០២២ ។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងបានចែកជូនកញ្ចប់អាហារសម្រាប់បួសជូនប្រជាពលរដ្ឋចំនួន១៥០គ្រួសារ នៅភូមិដំណាក់ចង្អើរ និងភូមិថ្មី សង្កាត់ព្រៃធំ ខេត្តតាកែវ នារសៀលថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ចំនួន៤៤០គ្រួសារ នៅភូមិតាដិប សង្កាត់អណ្តូងខ្មែរ ភូមិថ្មី សង្កាត់ព្រៃធំ ខេត្តតាកែវ នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណល និងសួរសុខទុក្ខប្រជាពលរដ្ឋចំនួន៣២៦គ្រួសារ នៅភូមិព្រៃនប់ ឃុំព្រៃនប់ ភូមិអណ្តូងថ្ម ឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងចែកកញ្ចប់អាហារសម្រាប់ស្រាយបួសជូនប្រជាពលរដ្ឋចំនួន២១០គ្រួសារ នៅភូមិត្រពាំងលើក ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ នារសៀលថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង នៅស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២។

-ចូលរួមពិធីចែកអំណោយកញ្ចប់អាហារសម្រាប់ស្រាយបួសប្រចាំថ្ងៃជូនប្រជាពលរដ្ឋ  ចំនួន១៥០គ្រួសារ នៅភូមិបឹងតារោង ឃុំព្រៃឃ្មុំ នៅស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ នៅឃុំតាសោម ស្រុកអង្គរជុំ ភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២៦ ខែមីនា ថ្ងៃទី២ និងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលនានាក្នុងវត្តនគរភាស និងជួបសំណេះសំណាលលោកតា លោកយាយចំនួន២០០នាក់ នៅឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។

❈នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **មួន ម៉ៃយ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីក្រុងពាលីសម្រាប់ទទួលទេវតាឆ្នាំថ្មី នៅក្នុងបរិវេណមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តរតនគីរី។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាគណៈអធិបតីភាពក្នុងពិធីសម្ពោធស្ពានបេតុងឆ្លងស្ទឹង-



សែន ខេត្តកំពង់ធំ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅវត្តកំពង់ស្វាយ ភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសកែសម្រួលសមាសភាពប្រធានកិត្តិយសគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកំពង់ធំ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅភូមិដំរីជាន់ខ្លា ឃុំដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នារសៀលថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។



-ចូលរួមជាកិត្តិយសក្នុងពិធីក្រុងពាលី និងអភិសេកព្រះ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិកម្ពុជា នៅវត្តតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសម្ពោធសាលាឆាន់ និងសមិទ្ធផលនានាក្នុងវត្តតាំងក្រសៅ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** ទេសាភិបាលនៃធនាគារជាតិកម្ពុជា វត្តតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។

❋ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ ក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបង នាថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២។

-ថ្វាយបង្គំ និងសួរសុខទុក្ខ នាំយកទេយ្យវត្ថុប្រគេនព្រះមេគណខេត្តបាត់ដំបង គង់នៅវត្តពោធិវាល មានព្រះជន្មាយុៈ៨៩ព្រះវស្សា និងបច្ច័យមួយចំនួនប្រគេនព្រះឥន្ទមុនី **អ៊ុក មុត** នៅខេត្តបាត់ដំបង នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។

❋នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ខេត្តតាកែវ។

❋ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាស្រុក ឃុំ និងប្រធានភូមិ ដើម្បីពិនិត្យការងារដែលដាក់ឱ្យអនុវត្ត និងការធ្វើបច្ចុប្បន្នភាព នៅសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។



-ចូលរួមក្នុងកិច្ចប្រជុំស្ដីពីវឌ្ឍនភាពការងារខែមីនា ឆ្នាំ២០២២ និងពិនិត្យរបាយការណ៍ផែនការទាំង១០ចំណុច ក្រោមអធិបតីភាព ឯកឧត្តម **គន់ គីម** ទេសរដ្ឋមន្ត្រី នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។

-នាំយកចង្ហាន់ និងទេយ្យទាន ព្រមទាំងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃគង់នៅវត្តកេសរារាម ហៅវត្តធម្មយុត្ត និងវត្ត



ព្រះព្រហ្មរតន៍ ស្ថិតនៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។



-ចូលរួមក្នុងកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាស្រុក អភិបាលស្រុក និងក្រុមប្រឹក្សាឃុំទាំង៦ ចំណុះស្រុកត្រពាំងប្រាសាទ ស្ដីពីការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅសាលប្រជុំសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីចែកសញ្ញាបត្រដល់និស្សិត នៃវិទ្យាស្ថានប្រាយហូម ដែលបានប្រឡងជាប់ បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ចំនួន៤៣០នាក់ នៅវិទ្យាស្ថានប្រាយហូប ភូមិធម្មយុត្តិ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំទាំង៥ និងភូមិទាំង២៩ សរុបចំនួន១៨៤នាក់ ដើម្បីឈ្វេងយល់ពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសមិទ្ធផលដែលជាព្រះរាជអំណោយ ព្រះមហាក្សត្រ ហ្លួងម៉ែ ជូនចំពោះកូនចៅព្រះអង្គ នៅសាលប្រជុំសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២។



-ចូលរួមជាមួយនឹងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ប្រធាន អនុប្រធានភូមិ តាជី យាយជី ចំនួន២៥នាក់ រៀបចំពិធីសូត្រមន្តលើករាសី ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងបង្សុកូលជូនដល់ដួងវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី និងមន្ត្រីរាជការ អ្នកស្នេហាជាតិ ដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិមាតុភូមិ នៅសាលាឃុំព្រៃគ្រី ស្រុកជល់គិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២ ។

❋ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំរដ្ឋបាលស្រុកដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំរដ្ឋបាលក្រុង

កែប ថ្នាក់ដឹកនាំយុវជន ក្រុង សង្កាត់ ក្រុមបណ្ដាញស្ត្រី ក្រុង សង្កាត់ ដើម្បីបន្តពង្រឹងការងារបោះឆ្នោត នៅក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសម្ពោធកុដិថ្មី និងសមិទ្ធផលនានាក្នុងវត្តព្រៃគុម្ព នៅភូមិព្រៃគុម្ព ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចុះត្រួតពិនិត្យការចាក់ដី និងជួសជុលផ្លូវជូនប្រជាពលរដ្ឋ នៅភូមិបុសរកា ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីចែកអំណោយ និងថវិកាជូនដល់ប្រជាពលរដ្ឋ នៅភូមិពោធិព្រឹក្សលិច ភូមិពោធិព្រឹក្សកើត និងភូមិស្នាកកណ្ដាល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៦ ខែមេសា ឆ្នាំ ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងនិវត្តជន នៃស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និងនិវត្តជននៃឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង នៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **ញ៉ៀម សាម៉ន** សមាជិកគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំទាំង៨ នៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ព្រមទាំងបានណែនាំឱ្យក្រុមប្រឹក្សាអនុវត្តនូវតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីបម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរ នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ទីស្នាក់ការឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នារសៀលថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ទីស្នាក់ការឃុំអូររ៉ៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នារសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២។

❈ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធាន អនុប្រធានភូមិ នៅឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំតាសោម ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តនគរភាស និងជួបសំណេះសំណាលជាមួយនឹងលោកតា លោកយាយប្រជាពលរដ្ឋ នៅឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងមន្ត្រីមន្ទីរកិច្ចការនារីខេត្តសៀមរាប ដើម្បីពិភាក្សាការងារអំពីកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការងារបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅសាលប្រជុំមន្ទីរកិច្ចកានារី ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងព្រឹត្តិការណ៍ "សៀមរាបសង្ក្រាន្ត" ដើម្បីអបអរសាទរ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅបរិវេណភូមិសង្ក្រាន្ត ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១៤ ថ្ងៃទី១៥ និងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❋នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៩រូប បានអញ្ជើញចូលរួមប្រជុំ ដើម្បីត្រៀមលក្ខណៈរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខាម ឃៀប** អនុប្រធានទី១រដ្ឋសភា នៅសាលប្រជុំបាយ័ន នៃវិមានរដ្ឋសភា។

❋ឯកឧត្តម **ជា ខេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបាន៖



-អនុញ្ញាតឱ្យថ្នាក់ដឹកនាំនៃក្រុមហ៊ុនផារ៉ាហ្គុន និងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គុន (PARAGON International University) ដឹកនាំដោយលោក **ដាមៀរ មូរសែវ** (Damir Musaev) នាយកប្រតិបត្តិក្រុមហ៊ុនផារ៉ាហ្គុន អញ្ជើញចូលជួបសម្តែងការគួរសម និងជូនពរក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ២៥៦៦ ព្រមទាំងអបអរសាទរក្នុងឱកាសដែលឯកឧត្តមទទួលបានគោរមងារកិត្តិយសពីរាជបណ្ឌិត្យសភាកម្ពុជា ជា "កិត្តិសេដ្ឋាបណ្ឌិត" នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២។



-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **អ៊ុំ សារិទ្ធ** សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅគេហដ្ឋានផ្ទះលេខ៤៨ ផ្លូវលេខ៣១៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។



-អញ្ជើញពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន ជាមួយនឹងថ្នាក់ដឹកនាំនៃក្រុមហ៊ុនផារ៉ាហ្គុន និងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គុន (PARAGON International University) នៅភោជនីយដ្ឋាន Halal Food 306 Gourmet Aged Wagyu ស្ថិតក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបលោក **សំ សុខឿន** ប្រធានសមាគមអចលនទ្រព្យសកល ព្រមទាំងសមាជិក សមាជិកាចំនួន៨រូប ចូល

ជួបសម្តែងការគួរសម និងសុំអនុញ្ញាតចុះមកពិនិត្យការអនុវត្តជាក់ស្តែង នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២។

-ចូលរួមពិធីសម្ពោធផ្សារជីបម៉ុង សែនសុខម៉ល ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅផ្សារជីបម៉ុង ខណ្ឌសែនសុខ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យសពកញ្ញា **សៀង សុរីណា** អាយុ ២៥ឆ្នាំ ទទួលមរណភាពដោយរោគាពាធ នៅឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីអភិសេក "បដិមាព្រះថោងនាងនាគ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២។

-ជួបជាមួយនឹងក្រុមអ្នកវិនិយោគទុនមកពីប្រទេសអ៊ុយក្រែន ដែលចង់បោះទុនវិនិយោគលើការចិញ្ចឹមឃ្មុំ នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២។

❋នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបាន អញ្ជើញទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូសភា នៃសាធារណរដ្ឋឥណ្ឌា នៅអាកាសយានដ្ឋានអន្តរជាតិ ភ្នំពេញ។

❋ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភា និងឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធ



បើកឱ្យប្រើប្រាស់ជាផ្លូវការ ផ្លូវជាតិលេខ៥១ ប្រវែងសរុប ៣៧,៩៥គីឡូម៉ែត្រ ចាប់ពីឧដុង្គ (ចំណុចប្រសព្វផ្លូវជាតិលេខ៥) ដល់ថ្នល់ទទឹង (ចំណុចប្រសព្វផ្លូវជាតិលេខ៤) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិថ្មគោល ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

❋ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធបើកឱ្យប្រើប្រាស់ ជាផ្លូវការ៖



-ស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិថ្នល់បំបែក សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។

-ហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន៣៨ខ្សែ និងសមិទ្ធផលនៃការស្តារកែលម្អដងស្ទឹងសៀមរាប នៅក្រុងសៀមរាប ខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គ-

មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២។

❈នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារជំងឺត្រចៀក ច្រមុះ និងបំពង់ក មិត្តភាពកម្ពុជា-កូរ៉េ នៃមន្ទីរពេទ្យព្រះអង្គឌួង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមន្ទីរពេទ្យព្រះអង្គឌួង។

❈ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន ឆ្នាំ២០២២ ជាមួយនឹងបណ្តាអង្គទូត នៃប្រទេសកាន់សាសនាឥស្លាម ប្រចាំព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំ និងសាសនិកខ្មែរឥស្លាមក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយុទ្ធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។



-ចូលរួមពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន ឆ្នាំ២០២២ ជាមួយនឹងថ្នាក់ដឹកនាំឥស្លាមកម្ពុជា និងឯកឧត្តម លោកជំទាវជាឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត នៃប្រទេសប្រ៊ុយណេដារ៉ូសាឡឹម ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូណេស៊ី ប្រទេសគុយវ៉ែត ប្រទេសតួកគី និងប្រទេសប៉ាគីស្ថាន នៅនិវេសនដ្ឋានឯកឧត្តម Pengiran Kasmirhan Pengiran Tahir ឯកអគ្គរាជទូតប្រ៊ុយណេដារ៉ូសាឡឹមប្រចាំព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២។

❈នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបាននាំយកចង្ហាន់ ទេយ្យវត្ថុ និងបច្ច័យមួយចំនួន ទៅប្រគេនព្រះសង្ឃ នៅវត្តសន្សំកុសល រាជធានីភ្នំពេញ។

❈ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រឿងញៀន នៅសាលបាយ័ន វិមានរដ្ឋសភា៕

## ការទទួលពាក្យបណ្តឹង

❈នៅក្នុងខែមេសា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន៦ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៣ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងចម្លងជូនគណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន៣ករណី៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងកំណត់ទិសដៅការងារខែមេសា ឆ្នាំ២០២២



*ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា*

នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងលើកទិសដៅការងារសម្រាប់ខែមេសា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាថា ខែមីនានេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបង្កើនការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការផ្ដល់សេវាតាមគន្លងថ្មីជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរ តាមតម្រូវការចាំបាច់ជាក់ស្ដែង ប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន។ ជាពិសេសក្នុងបរិបទនៃដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបន្តផ្ដោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្ដល់សេវាជូនគណៈកម្មការជំនាញទាំង១០ ចុះបំពេញបេសកកម្ម ជួបសវនាការការងារជាមួយនឹងក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធ ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយនឹងជំងឺកូវីដ-១៩ និងបាននាំយកគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាកនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានមានប្រសាសន៍បន្តទៀតថា ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូអន្តរជាតិ ជាពិសេសដំណើរបេសកកម្មនៅប្រទេសបារាំងទទួលបានលទ្ធផលល្អជាសក្ដានុពលថ្មីបន្ថែមទៀត ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីមានលក្ខណៈទាក់ទាញជាងមុន។

សម្រាប់ខែមេសាខាងមុខ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានកំណត់ឱ្យគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបន្តផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភាឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយលើមុខងារទាំង៥របស់ព្រឹទ្ធសភា ប្រកបដោយគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។ ជាមួយគ្នានេះ មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងលើកទិសដៅការងារខែមេសា ឆ្នាំ២០២២*

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ និងលើកទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២២



*ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា*

នាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ និងលើកទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២២ ក្រោមអធិ-បតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង នៅសាលសិក្ខាសាលាខាងជើង នៃវិមានព្រឹទ្ធសភា។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គ-លេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងត្រីមាសទី១ ឆ្នាំ២០២២ថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានអនុវត្តការងារលើមុខងារទាំង៥ សម្រេចបានលទ្ធផលល្អជាងត្រីមាសទី១ ឆ្នាំ២០២១ ទោះបីស្ថានភាពបន្តស្ថិតក្រោមឥទ្ធិពលនៃការរីករាលដាលជំងឺកូវីដ-១៩យ៉ាងណាក៏ដោយ។

លទ្ធផលទាំងនេះ បង្ហាញពីភាពឈ្លាសវៃរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ត្រីរាជការ ក្នុងការប្រតិបត្តិការងារតាមបែបគន្លងថ្មី និងបង្កើតបានភាពធន់ក្នុងការអនុវត្តមុខងាររៀងៗខ្លួន។

ឯកឧត្តមបានបញ្ជាក់ថា សកម្មភាពលេចធ្លោ គឺការយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋាន ក្នុងបរិបទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈការចុះប្រាស្រ័យទាក់ទងជាមួយនឹងប្រជាពលរដ្ឋ អាជ្ញាធរដែនដី ការចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងសមា-ជិកព្រឹទ្ធសភា ដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងក្ដាប់នូវស្ថានការណ៍ជាក់ស្ដែង ពិនិត្យតាមដានយន្តការនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំអំពីបញ្ហាប្រឈម និងសំណូមពរនានា ព្រមទាំងការចូលរួមចំណែកដល់ការអភិ-វឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ។ ចំពោះកិច្ចសហប្រតិ-បត្តិការអន្តរជាតិរយៈពេល ៣ខែ ដើមឆ្នាំ២០២២នេះ ទទួលបានលទ្ធផលល្អតាមរយៈការអនុវត្តការទូតសភាដ៏ទន់ភ្លន់ជាជំហានដ៏សំខាន់ទ្រទ្រង់ការលំបាករបស់យើង ក្នុងអំឡុងពេលជំងឺកូវីដ-១៩ នេះ។

សម្រាប់ទិសដៅការងារបន្ត ឯកឧត្តមអគ្គលេខាធិការបានកំណត់ឱ្យអង្គភាពចំណុះអគ្គលេខាធិកាដ្ឋានព្រឹទ្ធសភាបន្តប្រក្រតី-ភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែនទន់ភ្លន់ក្នុងសភាពការណ៍ចល័តដើម្បីធានាបរិមាណ និងគុណភាពការងារ។

ព្រមជាមួយគ្នានេះ មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ “៣ការពារ ៣កុំ” ឱ្យបានល្អប្រសើរ៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១*

## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលអាជ្ញាធរសង្កាត់ព្រែកតាសេក សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ គណៈកម្មការពិនិត្យវាយតម្លៃដំឡើងថ្នាក់បៀវត្ស នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើលក្ខណ-សម្បត្តិ និងពិនិត្យវាយតម្លៃសមត្ថភាពមន្ត្រីរាជការ ដែលជាបេក្ខជនត្រូវវាយតម្លៃដំឡើងថ្នាក់បៀវត្ស តាមវេនអតីត-ភាព និងវេនជ្រើសរើសសម្រាប់ឆ្នាំ២០២២ និងបញ្ហាផ្សេងៗ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតី-ភាពក្នុងពិធីប្រកាសឯកឧត្តម **លឹម ប៊ុនហុក** ជាអគ្គលេខា-ធិការរងថ្មី នៃព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង។



❈នាព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងលោកស្រី Mireille Eza នាយិកាកម្មវិធីនុមេរិក នៃសភាប្រើភាសាបារាំង នៅសាលប្រជុំពិសេសកណ្តាល នៃវិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **លឹម ប៊ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយនឹងលោក Etienne Fabrice ទីប្រឹក្សាទី១ និងលោក Hugo Warin លេខាទី១ នៃស្ថានទូតបារាំងប្រចាំនៅកម្ពុជា ដើម្បីពិភាក្សាត្រៀមរៀបចំកម្ម-វិធីដំណើរទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា របស់ក្រុមអន្តរសភាមិត្តភាពបារាំង-កម្ពុជា នៅសាលពិសេសកណ្តាល វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញស្ដាប់បទឧទ្ទេសនាមស្ដីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៅសាលពិសេសក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **ឈឹម ព្រះខ័ន** អគ្គនាយក តំណាងឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បាននាំយកសម្ភារ និងថវិកាទៅប្រគេនព្រះសង្ឃនៅវត្តបុទុមសាគរ ស្ថិតនៅភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នៅព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ លោកជំទាវ **សួន ពុធថាវី** អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងជាប្រធានគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយរបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ជូនអ្នកស្រី **ហេង សុធី** បានរងគ្រោះដោយសារប្ដីជះទឹកអាស៊ីតលើរាងកាយ កំពុងសម្រាកព្យាបាលជំងឺនៅផ្ទះ ស្ថិតនៅភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គាធិការដ្ឋាន និងអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដឹកនាំដោយលោកជំទាវ **រត្ន ឆវីលក្ខណ៍** អគ្គាធិការ នៃអគ្គាធិការដ្ឋាន បានអញ្ជើញនាំយកទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងបច្ច័យរបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ទៅប្រគេនព្រះសង្ឃគង់នៅវត្តមង្គលសត្ថាវ័ន្ត ស្ថិតក្នុងសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **លី រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោក **គីម សុគន្ធ** អតីតប្រធាននាយកដ្ឋានរដ្ឋបាល នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅផ្ទះលេខ២២៩ ផ្លូវលេខ២២៥ ភូមិព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។



